**អង្គការសហ**

**ប្រជាជាតិ**

**A**

*ការបកប្រែ*

*ក្រៅផ្លូវការ*

# មហាសន្និបាត

ការចែកចាយទូទៅ
A/HRC/4/36
ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧

ច្បាប់ដើម : ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

សម័យប្រជុំលើកទី៤

ចំណុចទី២ នៃរបៀបវារៈបណ្ដោះអាសន្ន

## ការអនុវត្តន៍សេចក្ដីសំរេចចិត្តរបស់មហាសន្និបាតលេខ៦០/២៥១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ដែលមានចំណងជើងថា "ក្រុមប្រឹក្សាសិទ្ធិមនុស្ស"

### របាយការណ៍របស់លោក យ៉ាស្ស ហ្គាយ តំណាងពិសេសនៃលោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

# សេចក្តីសង្ខេប

របាយការណ៍នេះ ត្រូវបានដាក់ស្នើស្របតាមសេចក្តីសំរេចលេខ១/១០២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

នៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍នេះ តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ធ្វើការបរិយាយអំពីបេសកកម្មលើកទីពីររបស់លោកមកកាន់ប្រទេសកម្ពុជា កាលពីខែមីនា ឆ្នាំ២០០៦ និងរៀបរាប់លំអិតអំពីការដែលលោកនៅតែមានកង្វល់ ដែលកង្វល់ទាំងនេះត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់របស់លោក ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស កាលពីខែកញ្ញាកន្លងមកនេះ ។

នៅក្នុងរបាយការណ៍នេះ លោកតំណាងពិសេស លើកឡើងអំពីបញ្ហាទាំងឡាយដែលមានចរិតជាប្រព័ន្ធមួយ ចាប់ពីទស្សនៈវិស័យនៃការប្តេជ្ញាចិត្តនានាក្នុងកិច្ចព្រមព្រៀងសន្តិភាព ដែលបានអនុម័តនៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។ កិច្ចព្រមព្រៀងទាំងនេះបានទទួលស្គាល់អំពីសារៈសំខាន់បំផុតនៃសិទ្ធិមនុស្សក្នុងការបង្កើត និងការរក្សាសន្តិភាព និងភាពរុងរឿងសំរាប់ប្រជាជនកម្ពុជាគ្រប់រូប ហើយរាល់បញ្ញត្តិដែលបានចែង សំដៅលើកស្ទួយសិទ្ធិមនុស្ស និងធានារ៉ាប់រងដោយរដ្ឋធម្មនុញ្ញដល់ការការពារសិទ្ធិទាំងនេះ ។

លោកបញ្ចប់របាយការណ៍ដោយភ្ជាប់ជាមួយនូវអនុសាសន៍មួយចំនួន ជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីធានាដល់ការគោរព និងការទទួលបានសិទ្ធិមនុស្សសំរាប់ប្រជាជនកម្ពុជាគ្រប់រូប ។

លោកតំណាងពិសេសកត់សំគាល់អំពីការចាប់ផ្តើមកិច្ចដំណើរការក្នុងអង្គជំនុំជំរះវិសាមញ្ញនៃតុលាការកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ជាងគេបំផុតចំពោះការប្រព្រឹត្តអំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គោលបំណងនៃការកាត់ទោសនេះ គឺដើម្បីទទួលស្គាល់អំពីតំលៃនៃសិទ្ធិមនុស្ស និងដើម្បីលើកស្ទួយការគោរពសិទ្ធិមនុស្ស ដើម្បីទទួលស្គាល់នូវអំពើអាក្រក់នៃនិទណ្ឌភាព និងដើម្បីពង្រឹងនីតិរដ្ឋ និងយន្តការនៃប្រព័ន្ធយុត្តិធម៌ ហើយវានឹងក្លាយទៅជាឥតខ្លឹមសារ ប្រសិនបើរដ្ឋាភិបាលមិនព្រមបញ្ឈប់ការអនុវត្តន៍ទាំងឡាយដែលបានចងក្រងក្នុងរបាយការណ៍នេះ និងក្នុងរបាយការណ៍មុនៗទៀតរបស់លោកតំណាងពិសេសដែលធ្វើឱ្យអន្តរាយដល់គោលដៅដ៏ពិសិដ្ឋទាំងអស់នេះ ។ លោកតំណាងពិសេស ក៏បានចង្អុលបង្ហាញអំពីការទទួលខុសត្រូវជាពិសេសរបស់សហគមន៍អន្តរជាតិ ចំពោះការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជាក្នុងបេសកកម្មរបស់ខ្លួន ដើម្បីពង្រឹងសិទ្ធិមនុស្ស និងធានាឱ្យមានយុត្តិធម៌សង្គម ។

# មាតិកា

| | | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|---|
| សេចក្តីផ្តើម | | ១ — ១៤ | ៤ |
| I. | ការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ | ១៥ — ២០ | ៨ |
| II. | ការដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្ស តាមរដ្ឋធម្មនុញ្ញ | ២១ — ៤០ | ៩ |
| | ក. ក្រុមប្រឹក្សាធម្មនុញ្ញ | ២១ — ៣០ | ៩ |
| | ខ. ឯករាជ្យភាពរបស់ចៅក្រម និងមេធាវី | ៣១ — ៤០ | ១២ |
| III. | សិទ្ធិការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តនៃការសំដែងមតិ សិទ្ធិបង្កើតសមាគម និងសិទ្ធិជួបប្រជុំ | ៤១ — ៥៥ | ១៤ |
| IV. | និទណ្ឌភាព និងការទទួលខុសត្រូវ | ៥៦ — ៦០ | ១៩ |
| V. | ការស្តារនីតិសម្បទា និងការស្ថាបនាប្រទេសកម្ពុជាឡើងវិញ ដោយមានការគោរព យ៉ាងពេញលេញដល់សិទ្ធិមនុស្សសំរាប់ទាំងអស់គ្នា | ៦១ — ៦៤ | ២០ |
| VI. | សិទ្ធិប្រើប្រាស់ដីធ្លី និងការចិញ្ចឹមជីវិត | ៦៥ — ៨៨ | ២២ |
| | ក. សម្បទានដីសេដ្ឋកិច្ច តាមផ្លូវច្បាប់ និងតាមការអនុវត្តន៍ជាក់ស្តែង | ៦៨ — ៧៤ | ២៣ |
| | ខ. តម្លាភាព និងការទទួលបានព័ត៌មាន | ៧៥ — ៧៩ | ២៥ |
| | គ. ជនជាតិដើមភាគតិច និងសិទ្ធិលើដីធ្លី | ៨០ — ៨៥ | ២៧ |
| | ឃ. ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធដីធ្លី និងធនធានធម្មជាតិ | ៨៦ — ៨៨ | ២៨ |
| VII. | សហគមន៍អន្តរជាតិ | ៨៩ — ៩៥ | ២៩ |
| VIII. | សេចក្តីសន្និដ្ឋាន | ៩៦ — ១០៥ | ៣១ |
| IX. | អនុសាសន៍ | ១០៦ — ១០៨ | ៣៣ |

# សេចក្តីផ្តើម

១.	របាយការណ៍នេះ ត្រូវបានដាក់ស្នើស្របតាមសេចក្តីសំរេចលេខ១/១០២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្នុងនោះ ក្រុមប្រឹក្សានេះបានសំរេចពន្យាពេលជាពិសេស សំរាប់រយៈពេលមួយឆ្នាំ ចំពោះអាណត្តិ និងអ្នកកាន់អាណត្តិនៃនីតិវិធីពិសេសទាំងអស់របស់គណៈកម្មការសិទ្ធិមនុស្ស ត្រូវស្ថិតក្រោមការពិនិត្យឡើងវិញថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស នឹងទទួលអនុវត្តបន្ត ស្របតាមសេចក្តីសំរេចចិត្តលេខ៦០/២៥១ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

២.	លោកតំណាងពិសេសបានបំពេញបេសកកម្មលើកទីពីរនៅកម្ពុជា ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦ ។ គោលបំណងចំបងនៃបេសកកម្មនេះ គឺដើម្បីពិភាក្សាពីរបាយការណ៍ និងអនុសាសន៍របស់លោក សំរាប់ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស នៅសម័យប្រជុំលើកទី៦២របស់ខ្លួន និងដើម្បីស្វែងយល់ថែមទៀតអំពីបញ្ហាទាំងឡាយដែលត្រូវបានផ្តោតការយកចិត្តទុកដាក់សំរាប់ការវិភាគរបស់លោកនៅក្នុងរបាយការណ៍នេះ ។

៣.	នៅក្នុងពេលបំពេញបេសកកម្មរបស់លោក លោកតំណាងពិសេសបានជួបពិភាក្សាការងារជាមួយលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ និងមន្ត្រីជាន់ខ្ពស់ដទៃទៀតនៃរដ្ឋាភិបាលកម្ពុជា ។ លោកក៏បានជួបជាមួយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការ មេដឹកនាំគណបក្សនយោបាយនានា តំណាងផ្សេងៗនៃអង្គការសិទ្ធិមនុស្ស អង្គការមេធាវីការពារជនក្រីក្រ សហជីពកម្មករ ក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី ព្រមទាំងសហគមន៍អ្នកការទូត ។ លោកតំណាងពិសេសបានធ្វើទស្សនកិច្ចទៅកាន់ខេត្តកំពង់ស្ពឺ និងខេត្តបាត់ដំបង ដែលនៅទីនោះ លោកបានជួបជាមួយជនរងគ្រោះដោយជំលោះដីធ្លី និងបានជួបជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរខេត្តនានា ។

៤.	នៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់លោកនៅពេលបញ្ចប់បេសកកម្មនេះ លោកតំណាងពិសេសបាន ស្វាគមន៍ការដោះលែងពីពន្ធនាគារ និងការវិលត្រឡប់មកកម្ពុជាវិញ កាលពីពាក់កណ្តាលខែមករា ឆ្នាំ២០០៥ នៃឥស្សរជនមួយចំនួនដែលសកម្មក្នុងជីវភាពសាធារណៈដែលត្រូវបានចោទប្រកាន់ផ្សេងៗគ្នាពីបទបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ កាលពីចុងឆ្នាំ២០០៥ ។ នៅពេលនោះដែរ លោកបានសំដែងនូវក្តីកង្វល់ ដោយសារការចោទប្រកាន់នៅតែមាននៅឡើយ ដែលនេះគឺជាការគំរាមកំហែងជានិច្ចដល់ការចាប់ខ្លួនជាថ្មី ចំពោះអ្នកដែលត្រូវបានដោះលែង ហើយរារាំងដល់អ្នកដទៃទៀត ពីការអនុវត្តន៍សេរីភាពនៃការសំដែងមតិ ។

៥.	លោកក៏បានស្វាគមន៍ ការវិលត្រឡប់មកវិញនៃមេដឹកនាំគណបក្សប្រឆាំងដ៏ចំបង ការដោះលែងពីពន្ធនាគារនៃសមាជិករដ្ឋសភានៃគណបក្សដដែលនេះ និងការទទួលបានមកវិញនូវអភ័យឯកសិទ្ធិសភារបស់ពួកគេ ។

៦.	លោកបានសន្និដ្ឋានថា ភាគច្រើននៃបញ្ហាសេសសល់ជាយូរមកហើយ ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់លោកនៅតែមានសុពលភាព និងនៅតែជាបញ្ហាបន្ទាន់បង្ខំដដែល ។ លោកតំណាងពិសេស បានគូសបញ្ជាក់ឡើងវិញអំពីអនុសាសន៍របស់លោកថា បទបញ្ញត្តិជាក់លាក់មួយចំនួនស្តីពីបទបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ( ដែលស្គាល់ជាទូទៅថា " ច្បាប់អ៊ុនតាក់ "[១] ) គួរត្រូវបានលុបចោលដោយគ្មានការពន្យាពេល ហើយមិនត្រូវរក្សាទុកបញ្ញត្តិស្តីពីការបរិហាកេរ្តិ៍ជាបទព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌថ្មីឡើយ ។ លោកបានកត់សំគាល់ឃើញថា ស្របគ្នានឹងមានការពិភាក្សាអំពីការបើកចំហថ្មីមួយច្បាប់ដែលបាននឹងកំពុងព្រាង អាចជាការដាក់កំរិតដល់សេរីភាព ក្នុងការបង្កើតសមាគមនិងការជួបប្រជុំ ។ លោកបានសំដែងនូវកង្វល់អំពីការជ្រៀតជ្រែកកិច្ចការតុលាការពីអំណាចនីតិប្រតិបត្តិនៅតែបន្តមាន និងអំពីអសមត្ថភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីបំពេញមុខងាររបស់ខ្លួនក្នុងការការពារបូរណភាព និងឯករាជ្យភាពរបស់ចៅក្រម ។ និទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ នៅតែចាក់ឫសយ៉ាងជ្រៅនៅប្រទេសកម្ពុជា ហើយបញ្ហានេះមិនអាចជំនះបានទេ ដោយសារប្រព័ន្ធតុលាការមួយលំអៀង មិនឯករាជ្យភាព និងគ្មានសមត្ថភាព ។

៧.	លោកតំណាងពិសេសមានកង្វល់ថា ការដណ្តើមយកដីធ្លីបានបន្តដកហូតសិទ្ធិលើដីធ្លី និងការចិញ្ចឹមជីវិតពីសហគមន៍ជនជាតិដើមភាគតិច និងប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ។ លោកបានផ្តល់អនុសាសន៍ឱ្យផ្អាកការផ្តល់សម្បទាន និងការលក់ដីធ្លីរបស់ជនជាតិដើមភាគតិចជាបណ្តោះអាសន្ន រហូតដល់មានគោលនយោបាយមួយច្បាស់លាស់និងច្បាប់ចាំបាច់ដើម្បីការពារសិទ្ធិជនជាតិដើមភាគតិចសិន ។ លោកបានសង្ឃឹមថា បរិយាកាសនយោបាយមួយដែលល្អប្រសើរ នឹងអាចបកស្រាយជាវិធានការជាក់លាក់ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់ការផ្លាស់ប្តូរជាក់ស្តែង និងពិតប្រាកដ ។

៨.	បន្ទាប់ពីបេសកកម្មរបស់លោក លោកតំណាងពិសេសបានពន្យល់នៅក្នុងលិខិតមួយច្បាប់ផ្ញើជូនលោកនាយករដ្ឋមន្ត្រីថា ចំណុចចាប់ផ្តើម និងក្របខ័ណ្ឌសំរាប់មុខងាររបស់លោក ជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ពឹងផ្អែកទាំងស្រុងលើរដ្ឋធម្មនុញ្ញកម្ពុជា និងការអនុវត្តន៍

---

[១] អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាជារដ្ឋភាគី ។ លោកបានស្វាគមន៍ដល់រដ្ឋាភិបាល ដែលបានបញ្ជាក់ពីការប្តេជ្ញាចិត្តចំពោះការផ្លាស់ប្តូរជាវិជ្ជមាន រួមទាំងវិស័យសិទ្ធិមនុស្សផង ហើយលោកបានពាំនាំកង្វល់របស់លោកជំរាបជូនលោកនាយករដ្ឋមន្ត្រី ។ លោកបានសំដែងពីបំណងប្រាថ្នារបស់លោក ដើម្បីធ្វើការក្នុងន័យស្ថាបនាជាមួយរដ្ឋាភិបាល និងទទួលបានប្រយោជន៍ពីទស្សនៈ និងការណែនាំពីលោកនាយករដ្ឋមន្ត្រី ដែលលោកមិនទាន់មានកិត្តិយសបានជួបប្រាស្រ័យនៅក្នុងការបំពេញអាណត្តិបេស់លោកនៅឡើយ ។

៩. លោកតំណាងពិសេសបានបង្ហាញរបាយការណ៍ និងអនុសាសន៍របស់លោកជូនក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីខែកញ្ញា ឆ្នាំ២០០៦ ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់លោកទៅកាន់ក្រុមប្រឹក្សានេះ លោកបានសំដែងការខកចិត្តថាមានតែអនុសាសន៍ចំនួនតិចតួចរបស់គាត់ និងរបស់តំណាងពិសេសមុនៗ ត្រូវបានយកមកអនុវត្ត ហើយថាការរំលោភសិទ្ធិមនុស្សនៅតែបន្តមានក្នុងទ្រង់ទ្រាយជាប្រព័ន្ធមួយ ហើយថាបញ្ហានេះមិនអាចបកស្រាយថាមកពីភាពក្រីក្រ ឬការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក្នុងកំឡុងកម្ពុជាប្រជាធិបតេយ្យឡើយ ។ លោកមានការសោកស្តាយចំពោះការត្រួតត្រាលើសលប់របស់គណបក្សកាន់អំណាចលើបរិយាកាសនយោបាយ ការធ្វើវិទ្ធង្សនារដ្ឋធម្មនុញ្ញនិងប្រព័ន្ធច្បាប់និងយុត្តិធមិការនាំឱ្យមានអំពើពុករលួយ និងផលប៉ះពាល់នៃការដណ្តើមយកដីធ្លី របស់ប្រជាជនក្រីក្រនៅតាមជនបទដោយខុសច្បាប់ ។ លោកបានគូសបញ្ជាក់អំពីការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ ចំពោះការជួយឧបត្ថម្ភគាំទ្រដល់ប្រជាជនកម្ពុជា ក្នុងបេសកកម្មរបស់ខ្លួន ដើម្បីយុត្តិធមិ និងការទទួលខុសត្រូវ ។ លោកបានបញ្ជាក់ថា លោកមិនបានវិនិច្ឆ័យខុសអំពីការលំបាកដែលប្រទេសនានាជួបប្រទះក្រោយពេលសង្គ្រាម និងជំលោះនោះទេ ។ លោកបានមកធ្វើទស្សនកិច្ចនៅកម្ពុជា ជាលើកដំបូងក្នុងឆ្នាំ១៩៩២ ហើយបានឃើញស្ថានភាពនៃប្រទេសនេះ កាលពីពេលនោះទើបតែងើបចេញពីចម្បាំង និងសង្គ្រាមស៊ីវិលរយៈពេលជាច្រើនឆ្នាំ ។ លោកបានទទួលស្គាល់អំពីការរីកចំរើនក្នុងការស្ថាបនាប្រទេសកម្ពុជាឡើងវិញ ។ ទោះជាយ៉ាងណាក៏ដោយ ១៥ឆ្នាំក្រោយពីការចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនាសន្និសិទក្រុងប៉ារីសស្តីពីកម្ពុជា ក្នុងខែតុលា ឆ្នាំ១៩៩១ បទបញ្ញត្តិភាគច្រើនពីសិទ្ធិមនុស្សដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ ។

១០. នៅក្នុងការបំពេញអាណត្តិរបស់លោក លោកតំណាងពិសេសបានបន្តធ្វើការតាមដានយ៉ាងជិតស្និទអំពីស្ថានការណ៍ក្នុងប្រទេសកម្ពុជា ហើយអនុវត្តតាមគោលការណ៍អាទិភាព ដែលមានចែងក្នុងសេចក្តីសំរេចចិត្តលេខ ២០០៥/៧៧ របស់គណៈកម្មការសិទ្ធិមនុស្ស ។ ក្នុងរបាយការណ៍នេះលោកតំណាងពិសេស មានទស្សនៈសំរាប់រយៈពេលវែងដោយផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាទាំងឡាយដែលមានចរិតជាប្រព័ន្ធ ដែលចាំបាច់ត្រូវតែដោះស្រាយ ប្រសិនបើប្រទេសកម្ពុជាចង់ឱ្យមានការរីកចំរើន ហើយប្រជាជនរបស់ខ្លួនមានជីវភាពរស់នៅសមរម្យនោះ ។

១១.	ឆ្នាំ២០០៦ គឺជាខួបទី១៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ហើយវាគឺជាពេលវេលាមួយដ៏សមស្រប ដើម្បីវាយតំលៃពីការអនុវត្តន៍បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។ ឯកសារនីមួយៗ ក្នុងចំណោមឯកសារចំនួនបី ដែលត្រូវបានអនុម័តដោយសន្និសិទនេះ រួមមានកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយទូទៅនៃជំលោះកម្ពុជា កិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាពបូរណភាពទឹកដី និងភាពមិនអាចរំលោភបំពានបាន អព្យាក្រិត្យភាព និងឯកភាពជាតិនៃកម្ពុជា និងសេចក្តីប្រកាសស្តីពីការស្តារនិងការស្ថាបនាប្រទេសកម្ពុជាឡើងវិញ សុទ្ធតែបានទទួលស្គាល់អំពីសារៈសំខាន់ជាសារវ័ន្តនៃការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស ក្នុងការបង្កើតនិងការរក្សាសន្តិភាព និងភាពរុងរឿងដល់ប្រជាជនកម្ពុជាគ្រប់រូប និងមានបទបញ្ញត្តិសំរាប់ការលើកស្ទួយសិទ្ធិមនុស្ស ក៏ដូចជាការធានារ៉ាប់រងដោយរដ្ឋធម្មនុញ្ញចំពោះការការពារសិទ្ធិទាំងនេះ ។

១២.	នៅក្នុងកិច្ចព្រមព្រៀងទាំងនេះ អាជ្ញាធរកម្ពុជាបានទទួលភារកិច្ចការពារសិទ្ធិមនុស្សនិងធានាថា គោលនយោបាយនិងការអនុវត្តន៍នានាពីអតីតកាលមិនត្រូវឱ្យវិលត្រឡប់មកវិញឡើយ ។ ដោយកត់សំគាល់ថា "ប្រវត្តិសាស្ត្រថ្មីៗដ៏សោកនាដកម្មរបស់កម្ពុជា ទាមទារនូវវិធានការពិសេស ដើម្បីធានាដល់ការលើកស្ទួយសិទ្ធិមនុស្ស " ទើបកិច្ចព្រមព្រៀងទាំងនេះ ចែងលំអិតអំពីបទបញ្ញត្តិស្តីពីសិទ្ធិមនុស្ស ដើម្បីដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញថ្មី ដែលគួរចែងអំពីសេចក្តីប្រកាសស្តីពីសិទ្ធិជាសារវ័ន្ត ។ សិទ្ធិទាំងនេះគួរត្រូវបានអនុវត្តដោយតុលាការមួយឯករាជ្យ ហើយ "ជនរងគ្រោះ" គួរតែអាចអនុវត្តសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការ ។ ការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍អន្តរជាតិ ក៏ជាផ្នែកស្នូលមួយនៃកិច្ចព្រមព្រៀងនេះដែរ ។

១៣.	កិច្ចព្រមព្រៀងទាំងនេះ មានប្រសិទ្ធភាពជារៀងរហូត ទោះជាក្រោយពីការបញ្ចប់ទៅនៃសម័យអន្តរកាលក៏ដោយ ។ កិច្ចព្រមព្រៀងទាំងនេះបានចែងអំពីការបន្តគោរពនិងប្រតិបត្តិសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ក្នុងការធ្វើសកម្មភាពផ្សេងៗ ដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត វិធានការដ៏មានប្រសិទ្ធភាព ដើម្បីធានាថាគោលនយោបាយ និងការអនុវត្តន៍ទាំងឡាយពីអតីតកាលមិនត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់មកវិញ ការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ការស្តារនិងការស្ថាបនាប្រទេសកម្ពុជាឡើងវិញ ដោយមានការគោរពយ៉ាងពេញលេញដល់សិទ្ធិមនុស្សសំរាប់ទាំងអស់គ្នា និងភារកិច្ចរបស់ប្រទេសហត្ថលេខីដទៃទៀត ដើម្បីលើកស្ទួយ និងជំរុញឱ្យមានការគោរព និងការប្រតិបត្តិសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តនៅកម្ពុជា ដូចមានចែងក្នុងលិខិតុបករណ៍អន្តរជាតិ ។

១៤.	កិច្ចព្រមព្រៀងនេះ បានផ្តល់ឱ្យគណៈកម្មការសិទ្ធិមនុស្សនូវអាណត្តិបន្ត ដើម្បីឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សបន្ទាប់ពីការបញ្ចប់ទៅនៃសម័យអន្តរកាល រួមទាំងមានការតែងតាំងអ្នករាយការណ៍ពិសេសមួយរូបផងដែរ ។ ចាប់តាំងពីឆ្នាំ១៩៩៣មក លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានតែងតាំងតំណាងពិសេសចំនួនបួនរូបទទួលបន្ទុកសិទ្ធិ

មនុស្សនៅកម្ពុជា ដែលតំណាងម្នាក់ៗត្រូវបានផ្ទុកដាក់ឱ្យរក្សាទំនាក់ទំនងជាមួយរដ្ឋាភិបាលនិងប្រជាជនកម្ពុជា និងជួយរដ្ឋាភិបាលក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។ គណៈកម្មការសិទ្ធិមនុស្ស និងមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនស្តីពីប្រទេសកម្ពុជា បានគាំទ្រនិងជំរុញរដ្ឋាភិបាល ឱ្យពង្រឹងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រតិបត្តិតាមនីតិរដ្ឋ និងសិទ្ធិមនុស្សថែមទៀត ។

## I. ការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ

១៥. ប្រទេសកម្ពុជា បានចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ហើយនៅឆ្នាំ១៩៩២ បានចូលជាភាគីនៃសិទ្ធិសញ្ញាចំនួន៥ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាំង៦ ។ កម្ពុជាបានផ្តល់សច្ចាប័នជាបន្តបន្ទាប់លើពិធីសារបន្ថែមចំនួនពីរទៀតស្តីពីសិទ្ធិកុមារ ។ កម្ពុជាមិនមែនជាភាគីនៃពិធីសារបន្ថែមទីពីរលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ ទោះបីជារដ្ឋធម្មនុញ្ញបានលុបចោលទោសប្រហារជីវិតហើយក៏ដោយ ហើយកម្ពុជាមិនបានទទួលយកការទំនាក់ទំនង ឬការស៊ើបសួរជាឯកត្តបុគ្គល ក្រោមសន្ធិសញ្ញាដែលចែងអំពីនិតិវិធីទាំងនេះទេ ។

១៦. កាលពីខែវិច្ឆិកា ឆ្នាំ២០០៦ រដ្ឋសភាបានចាប់ផ្តើមកិច្ចដំណើរការផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលកម្ពុជាបានចុះហត្ថលេខាក្នុងខែកញ្ញា ឆ្នាំ២០០៥ ។ លិខិតុបករណ៍អន្តរជាតិបន្ថែមមួយចំនួនទៀត ស្តីពីសិទ្ធិមនុស្សត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា តាមរយៈមាត្រា៧៤ នៃច្បាប់អ៊ុនតាក់ ។

១៧. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ចែងពីការធានាជាមូលដ្ឋាននៃសិទ្ធិមនុស្ស ។ តាមរយៈមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត ត្រូវបានផ្តល់នូវអានុភាពគតិយុត្តិ ។ មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញ ធានារ៉ាប់រងជាពិសេសដល់ការការពារសិទ្ធិកុមារ ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

១៨. នៅពេលដែលលោកតំណាងពិសេស បានជួបជាមួយប្រធាន និងសមាជិកមួយចំនួននៃក្រុមប្រឹក្សាធម្មនុញ្ញនៅក្នុងពេលបំពេញបេសកកម្មលើកទីពីររបស់លោក ដើម្បីពិភាក្សាអំពីតួនាទីរបស់ក្រុមប្រឹក្សានេះ ក្នុងការពង្រឹងការធានាការពារសិទ្ធិមនុស្សតាមរដ្ឋធម្មនុញ្ញ លោកតំណាងពិសេសមានកង្វល់ អំពីហេតុដែលថា សមាជិកខ្លះនៅមាន

មន្ទិលអំពីការអនុវត្តសន្ធិសញ្ញាទាំងនេះដោយផ្ទាល់ នៅក្នុងច្បាប់កម្ពុជាបើទោះជាមានចែងនៅក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញក៏ដោយ ។

១៩. ដោយសាររដ្ឋធម្មនុញ្ញមិនបានចែងលំអិតអំពីសិទ្ធិដែលខ្លួនធានាការពារ សិទ្ធិសញ្ញាសិទ្ធិមនុស្សផ្តល់នូវការបរិយាយសំខាន់ៗយ៉ាងស៊ីជំរៅពីខ្លឹមសារនៃសិទ្ធិទាំងអស់នោះ ។ ប្រសិនជាក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងតួនាទីជាអ្នកធានាការពាររដ្ឋធម្មនុញ្ញ មិនបានត្រៀមខ្លួនលើកកំពស់សិទ្ធិសន្ធិសញ្ញាដែលបានការពារដោយរដ្ឋធម្មនុញ្ញ ប្រឆាំងនឹងការរំលោភបំពានពីច្បាប់ជាបន្តបន្ទាប់ទេនោះ សិទ្ធិមនុស្សមិនអាចត្រូវបានការពារយ៉ាងពេញលេញឡើយ ហើយការអះអាងរបស់កម្ពុជាថា សន្ធិសញ្ញាអន្តរជាតិទាំងនេះមានអានុភាពខ្ពស់ជាងច្បាប់ជាតិនោះ គឺមិនអាចរក្សាបានឡើយ ។

២០. នៅពេលដែលការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ត្រូវបានទះដៃអបអរសាទរក៏ដោយ ដើម្បីការពារសិទ្ធិមនុស្ស និងបំពេញបានកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួននោះ រដ្ឋាភិបាលក៏ត្រូវធានាថា បុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបានក្រោមនីតិរដ្ឋ ហើយទាមទារឱ្យមានការដោះស្រាយប្រកបដោយប្រសិទ្ធភាព នៅពេលដែលមានការរំលោភសិទ្ធិទាំងនេះ ។

## II. ការដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្សតាមរដ្ឋធម្មនុញ្ញ

២១. សិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយតុលាការជាតិដែលមានសមត្ថកិច្ច ចំពោះអំពើរំលោភសិទ្ធិទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ គឺជាគោលការណ៍ជាសារវន្តមួយស្តីពីសិទ្ធិមនុស្ស ។ ក្នុងការអនុវត្តន៍ ទាំងការធានាការពារសិទ្ធិមនុស្សដោយរដ្ឋធម្មនុញ្ញ ទាំងស្ថាប័នទាំងឡាយដែលបង្កើតដោយរដ្ឋធម្មនុញ្ញ ដើម្បីអនុវត្តសិទ្ធិទាំងនោះ មិនបានធ្វើការដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្សឡើយ ។

### ក. ក្រុមប្រឹក្សាធម្មនុញ្ញ

២២. ក្រុមប្រឹក្សាធម្មនុញ្ញ ដែលទទួលខុសត្រូវការពារ និងបកស្រាយរដ្ឋធម្មនុញ្ញ បានបង្ហាញពីសញ្ញាវិរែកក្នុងការប្រឈមមុខជាមួយច្បាប់របស់រដ្ឋាភិបាល លើមូលដ្ឋានដែលថាច្បាប់នេះរំលោភលើការធានាការពារសិទ្ធិមនុស្ស ។ ក្នុងខែធ្នូ ឆ្នាំ២០០៤ ក្រុមប្រឹក្សានេះបានអះអាងអំពីធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម ឆ្នាំ១៩៩១ ទោះបីជាទស្សនៈទូទៅយល់ថា ច្បាប់នេះបានរំលោភសិទ្ធិក្នុងការប្រមូលផ្តុំដោយសន្តិវិធី ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញក៏ដោយ ។ ក្នុងខែ វិច្ឆិកា ឆ្នាំ២០០៦ ក្រុមប្រឹក្សានេះបានតំកល់ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដោយបដិសេធពាក្យ

ស្នើសុំពីក្រុមតំណាងរាស្ត្រគណបក្សប្រឆាំងដែលប្តឹងថា ច្បាប់នេះបានបំពានលើការធានាការពារដោយរដ្ឋធម្មនុញ្ញនៃបញ្ញត្តិអភ័យឯកសិទ្ធិសភា និងសិទ្ធិមានសេរីភាពក្នុងការសំដែងមតិ ។

២៣. ការប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលបានប្រកាសឱ្យប្រើកាលពីខែមករា ឆ្នាំ ២០០២ ដើម្បីបង្កើនទម្ងន់ទោស បង្ហាញពីការខកខាននៃស្ថាប័នទាំងឡាយ ដែលបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ដូចជារដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការ មិនបានលើកស្ទួយសិទ្ធិដែលបានធានាការពារនៅក្នុងរដ្ឋធម្មនុញ្ញ និងមិនបានធានាថា កុមារទទួលបានការការពារ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

២៤. នៅពេលដែលសេចក្តីព្រាងច្បាប់កំពុងត្រូវបានជជែកពិភាក្សានៅព្រឹទ្ធសភា នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០១ សមាជិកព្រឹទ្ធសភា៣៤រូប ក្នុងចំណោមសមាជិកព្រឹទ្ធសភា៥១រូប បានបោះឆ្នោតប្រឆាំងសេចក្តីព្រាងច្បាប់នេះ ។ សមាជិកព្រឹទ្ធសភាបីរូប ដែលសំដែងមតិប្រឆាំងនឹងសេចក្តីព្រាងច្បាប់នេះ ត្រូវបានគណបក្សប្រជាជនកម្ពុជាបណ្តេញចេញពីការងារភ្លាម គឺជាករណីមួយដែលត្រូវបានសហភាពអន្តរសភាធ្វើការតាមដានជាបន្តបន្ទាប់មក ។ នៅពេលដែលសេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ជូនត្រឡប់ទៅរដ្ឋសភាវិញ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានបញ្ជូនច្បាប់នេះថ្វាយព្រះមហាក្សត្រ ដោយមិនបានធ្វើការជជែកពិភាក្សាបន្ថែមទៀតឡើយ ។

២៥. ច្បាប់នេះ បានកែប្រែខ្លឹមសារបញ្ញត្តិច្បាប់ព្រហ្មទណ្ឌមួយចំនួន ។ មាត្រា៨ បង្ខំឱ្យចៅក្រមអនុវត្តទោសអតិបរមាចំពោះជនទាំងឡាយដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ដោយបដិសេធចោលកាតព្វកិច្ចដែលបានកំណត់ឱ្យចៅក្រម តាមមាត្រា៦៨(១) នៃច្បាប់អ៊ុនតាក់ ឱ្យថ្លឹងថ្លែងពីស្ថានសំរាលទោស និងបន្ធូរបន្ថយទោសក្រោមទណ្ឌកម្មអប្បបរមាដែលមានចែងក្នុងច្បាប់ និងអនុញ្ញាតឱ្យមានការព្យួរទោស ។ មាត្រា៨ ក៏បានធ្វើនិរាករណ៍មាត្រា៦៨(២) នៃច្បាប់អ៊ុនតាក់ ដែលអនុញ្ញាតឱ្យញែកចេញជាពីរនូវទោសជាប់ពន្ធនាគារ ចំពោះអនីតិជនអាយុក្រោម១៨ ឆ្នាំ ។

២៦. នៅក្នុងពេលបំពេញបេសកកម្មលើកទី២របស់លោក លោកតំណាងពិសេសបានជួបជាមួយតំណាងនានានៃអង្គការ មេធាវីការពារជនក្រីក្រ ដែលតំណាងទាំងនោះ បានទាញចំណាប់អារម្មណ៍របស់លោក អំពីផលប៉ះពាល់ធ្ងន់ធ្ងរនៃបទបញ្ញត្តិតឹងតែងពេកនៃច្បាប់នេះចំពោះកុមារ និងផលប៉ះពាល់ដែលកើតឡើងដោយសារនិយមន័យនៃបទល្មើសលួចណាដែលពាក់ព័ន្ធមនុស្សពីរនាក់ឬច្រើននាក់ជាបទឧក្រិដ្ឋ ។ ទោះបីជាចៅក្រមភាគច្រើនបង្ខំចិត្តអនុវត្តច្បាប់នេះក៏ដោយ ក៏ចៅក្រមមួយចំនួនបានបន្តអនុវត្តច្បាប់អ៊ុនតាក់ ចំពោះករណីអនីតិជនដែរ ។

២៧. ផលប៉ះពាល់នៃច្បាប់នេះ ហាក់ដូចជាបង្កើត**ការបំពានជាចំហដំបូងមួយ** នៃកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជា ក្នុងការពិចារណាពីជំរើសទោសអប្បបរមា និងមិនឃុំឃាំងចំពោះអនីតិជន អនុលោមតាមមាត្រា៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ដូច្នេះ ច្បាប់នេះមិនស្របតាមមាត្រា៣១ និងមាត្រា៤៨ នៃរដ្ឋធម្មនុញ្ញ ដែលធានាការពារជាពិសេសដល់អនុសញ្ញានេះទេ ។ ទោះជាយ៉ាងណាក៏ដោយ គ្មានការប៉ុនប៉ងណាមួយដើម្បីស្នើឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះទេ ទោះជាតាមរយៈតុលាការ ឬតាមរយៈក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក្តី ។

២៨. អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ដែលកំពុងអនុវត្ត បុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងតាមផ្លូវច្បាប់ អាចស្នើឱ្យតុលាការពិចារណាពីធម្មនុញ្ញភាពនៃច្បាប់ ឬសេចក្តីសំរេចណាមួយរបស់ស្ថាប័នរដ្ឋ ដែលប៉ះពាល់ដល់សិទ្ធិ និងសេរីភាពជាសារវន្តរបស់ខ្លួនបាន ដូច្នេះវាមិនត្រឹមតែផ្តល់ឱ្យចុងចោទនូវសិទ្ធិមួយដ៏សំខាន់ ដើម្បីតវ៉ាអំពីធម្មនុញ្ញភាពនៃច្បាប់ប៉ុណ្ណោះទេ តែថែមទាំងសេចក្តីសំរេចរបស់អំណាចនីតិប្រតិបត្តិ ដែលប្រឆាំងនឹងខ្លួនទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិនេះអាចត្រូវបានបដិសេធដោយវិធានប្រទាំងប្រទិស ដែលតុលាការកំពុងកាត់ក្តីត្រូវតែសំរេចជាមុន ថាតើមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ហើយឬនៅ ចំពោះការអះអាងថាច្បាប់នេះអធម្មនុញ្ញភាពនោះ ។ បន្ទាប់មកតុលាការត្រូវបញ្ជូនបញ្ហានេះទៅតុលាការកំពូលក្នុងរយៈពេល១០ថ្ងៃ ។ តុលាការកំពូលមានពេល១៥ថ្ងៃ ដើម្បីសំរេចថាតើករណីនេះ "អាចទទួលយកបាន" ហើយប្រសិនជាអាចទទួលយកបាន ត្រូវបញ្ជូនបញ្ហានេះទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីសំរេច ។ កន្លងមកមិនមានករណីណាមួយដែលថា តុលាការផ្តួចផ្តើមនីតិវិធីនេះទេ ។

២៩. បុគ្គលទាំងឡាយដែលមិនពាក់ព័ន្ធក្នុងរឿងក្តីនៅតុលាការ តាមរដ្ឋធម្មនុញ្ញ មានសិទ្ធិតិចតួចបំផុតស្វែងរកការជួយឧបត្ថម្ភពីក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីទាមទារសិទ្ធិតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន ។ ក្រុមប្រឹក្សានេះក៏មិនអាចផ្តួចផ្តើមគំនិតដោយខ្លួនឯងពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាតិដែរ ។ ការពិនិត្យធម្មនុញ្ញភាពអាចធ្វើបាន តែតាមការស្នើសុំពីព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួនប៉ុណ្ណោះ ។ ប្រជាពលរដ្ឋអាចស្នើឱ្យតំណាងរាស្ត្ររបស់ខ្លួន បញ្ជូនករណីរបស់ខ្លួនទៅក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្តែមិនអាចប្តឹងឧទ្ធរណ៍អំពីសិទ្ធិរបស់ខ្លួនបានឡើយ បើការស្នើសុំនោះត្រូវបានបដិសេធ ។ ក្នុងចំណោម៣៦ករណី ដែលបានចុះផ្សាយក្នុង*រាជកិច្ច* ចាប់តាំងពីខែកក្កដា ឆ្នាំ១៩៩៨ ដែលបានតវ៉ាអំពីធម្មនុញ្ញភាពនៃច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញបានរកឃើញតែ៥ករណីប៉ុណ្ណោះដែលអធម្មនុញ្ញភាព ហើយករណីនីមួយៗនៃសំណើ ត្រូវបានដាក់ស្នើដោយឥស្សរជនមួយចំនួនដែលមាននិន្នាការជាមួយរដ្ឋាភិបាល ។

៣០. លោកតំណាងពិសេសរំលឹកឡើងវិញ និងគូសបញ្ជាក់ជាថ្មីនូវកង្វល់របស់លោក អំពីភាពមិនលំអៀងនៃក្រុមប្រឹក្សាធម្មនុញ្ញដែលនៅតែជាបញ្ហា បើតាមស្មារតីនៃសមាសភាពបច្ចុប្បន្នរបស់ខ្លួន និងនិន្នាការនៃសមាជិក៦រូបក្នុងចំណោមសមាជិកទាំងអស់៩រូប ជាមួយគណបក្សប្រជាជនកម្ពុជា ។

## ខ. ឯករាជ្យភាពរបស់ចៅក្រម និងមេធាវី

៣១. ឯករាជ្យភាពរបស់ចៅក្រមត្រូវបានតំកល់នៅក្នុងរដ្ឋធម្មនុញ្ញ ហើយត្រូវបានធានាការពារបន្ថែមទៀតនៅក្នុងនីតិវិធីព្រហ្មទណ្ឌ តាមរយៈមាត្រា១នៃច្បាប់អ៊ុនតាក់ ហើយត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់កម្ពុជានូវ "គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ" ។ ការខ្វះឯករាជ្យភាពរបស់តុលាការ និងអសមត្ថភាពរបស់ខ្លួន ដើម្បីទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ចំពោះការរំលោភសិទ្ធិមនុស្ស បានក្លាយជាបញ្ហាព្រួយបារម្ភឥតឈប់ឈរដល់លោកតំណាងពិសេសទាំងអស់ ហើយត្រូវបានធ្វើការកត់សំគាល់ដដែលៗ ក្នុងសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ និងគណៈកម្មការសិទ្ធិមនុស្ស ។

៣២. ក្នុងការអនុវត្តជាក់ស្តែង តុលាការមិនអាចមានលទ្ធភាពអនុវត្តប្រកបដោយប្រសិទ្ធភាព តទល់នឹងអំណាចនីតិប្រតិបត្តិទេ ។ ចៅក្រមនៅតែបន្តស្ថិតក្រោមការជ្រៀតជ្រែកខាងនយោបាយ ហើយមិនអាច ឬមិនមានឆន្ទៈអនុវត្តមុខងាររបស់ខ្លួនដោយឯករាជ្យឡើយ ។ អំពើពុករលួយនៅតែបន្តកើតមានគ្រប់ទីកន្លែង ។

៣៣. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នធម្មនុញ្ញមួយទទួលបន្ទុកការពារឯករាជ្យភាព និងបូរណភាពវិជ្ជាជីវៈរបស់ចៅក្រម រួមទាំងព្រះរាជអាជ្ញា ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាមិនអាចបំពេញតួនាទីរបស់ខ្លួនដែលគួរឱ្យជឿទុកចិត្តបាន និងប្រកបដោយប្រសិទ្ធភាពឡើយ ។ ដូចដែលលោកតំណាងពិសេសបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ចុងក្រោយរបស់លោកថា ឧត្តមក្រុមប្រឹក្សានេះត្រូវធ្វើកំណែទម្រង់ទាំងស្រុង ស្របតាមគោលការណ៍នៃការបែងចែកអំណាចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីឱ្យសមាសភាពក្រុមប្រឹក្សានេះ តំណាងឱ្យវិជ្ជាជីវៈតុលាការមិនទទួលឥទ្ធិពលនយោបាយ ។ វាជាការពិបាកណាស់ថាតើឯករាជ្យភាពរបស់ចៅក្រមអាចត្រូវបានធានាយ៉ាងដូចម្តេចកាលបើស្ថាប័ននិយតកម្មរបស់ខ្លួន មានសមាជិកម្នាក់ជារដ្ឋមន្ត្រីក្នុងតំណែងរបស់រដ្ឋាភិបាល និងម្នាក់ទៀតជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សកាន់អំណាច ។ ចៅក្រមក៏ដូចជាប្រជាពលរដ្ឋឯទៀតដែរមានសេរីភាពក្នុងការសំដែងមតិសិទ្ធិខាងជំនឿ សិទ្ធិបង្កើតសមាគម និងសេរីភាពក្នុងការប្រមូលផ្តុំ ប៉ុន្តែក្នុងការអនុវត្តន៍សិទ្ធិទាំងនេះ ចៅក្រមត្រូវប្រកាន់ខ្ជាប់ជានិច្ច ដើម្បីរក្សាសេចក្តីថ្លៃថ្នូរនៃស្ថាប័នរបស់ខ្លួន និងភាពមិនលំអៀង និងឯករាជ្យភាពនៃតុលាការ ។ នៅក្នុងលិទ្ធិប្រជាធិបតេយ្យ តុលាការមិនត្រឹមតែឯករាជ្យប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើយ៉ាងណាឱ្យមើលឃើញថាពិតជាឯករាជ្យមែន ។

៣៤. សេចក្តីស្នើវិសោធនកម្មចំពោះច្បាប់ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានឈប់នៅទ្រឹង រង់ចាំការបញ្ចប់នៃច្បាប់ស្តីពីការចាត់តាំងតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលស្ថានភាពនិងលក្ខខណ្ឌការងាររបស់ពួកគេ នៅតែត្រូវធ្វើនិយតកម្មដោយច្បាប់ដែលរប៉ាត់រប៉ាយ

និងមិនច្បាស់លាស់ ដែលបានរៀបចំឡើងដោយឈរលើមូលដ្ឋានបណ្ដោះអាសន្ន តាំងពីមានច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ មកម្ល៉េះ ។

៣៥.	ច្បាប់មួយសំរាប់ការពាររយៈពេលកាន់មុខតំណែង ដំណើរការតែងតាំង ក្រមសីលធម៌ ប្រាក់កំរៃ និងរចនាសម្ព័ន្ធ ប្រាក់បៀវត្សរ៍មួយច្បាស់លាស់សំរាប់ចៅក្រម គួរតែត្រូវបានរៀបចំព្រាងភ្លាម១ បន្ទាប់ពីមានរដ្ឋធម្មនុញ្ញម្ល៉េះ ។ លោកតំណាងពិសេសយល់ឃើញថា ការព្រាងច្បាប់ទាំងបីនេះ គួរត្រូវបានសម្របសម្រួលនៅក្នុងកំណែទម្រង់មួយជាមួយគ្នាដោយសំអាងលើរដ្ឋធម្មនុញ្ញ គោលការណ៍ជាមូលដ្ឋានស្ដីពីឯករាជ្យភាពរបស់តុលាការ និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ ។ ការកែទំរង់នេះនឹងអាចធានាថា ការប្ដេជ្ញាចិត្តដែលបានធ្វើនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពដើម្បីអភិវឌ្ឍន៍ប្រព័ន្ធតុលាការនៅតែត្រូវបានប្រកាន់យក ។

៣៦. ប្រព័ន្ធចោទប្រកាន់ធ្វើឱ្យខូចដល់ប្រព័ន្ធយុត្តិធម៌ ។ ព្រះរាជអាជ្ញាជាច្រើនមិនបានបំពេញនូវបទដ្ឋានជាតិ និងអន្តរជាតិ ដែលធានាថា ការស៊ើបអង្កេត និងការចោទប្រកាន់ត្រូវធ្វើឡើងដោយមិនលំអៀង និងដោយសេចក្ដីសុចរិត និងក្នុងប្រយោជន៍សាធារណៈជាជាងប្រយោជន៍បក្សពួក ។ បណ្ដឹងដែលប្ដឹងដោយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ទោះបីជាបណ្ដឹងទាំងនោះផ្អែកលើភស្ដុតាងមិនធ្ងន់ធ្ងរ ឬមិនរឹងមាំក៏ដោយ ក៏ត្រូវធ្វើការចោទប្រកាន់ដោយយកចិត្តទុកដាក់ដែរ ចំណែកឯបណ្ដឹងភាគច្រើនលើសលុបរបស់ប្រជាពលរដ្ឋតូចតាច មានសង្ឃឹមតិចតួចណាស់ ថាព្រះរាជអាជ្ញានឹងលើកយកមកពិចារណា ។

៣៧.	ឯករាជ្យភាពរបស់មេធាវីមានសារសំខាន់ណាស់ចំពោះសិទ្ធិការពារប្រកបដោយប្រសិទ្ធភាព ដែលត្រូវបានធានាការពារក្នុងរដ្ឋធម្មនុញ្ញ ។ អនុលោមតាមនីតិវិធីត្រឹមត្រូវ ដែលបានធានាការពារក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស និងការការពារចុងចំលើយ ដែលបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញមាត្រា៣៨ រដ្ឋាភិបាលមានភារកិច្ចធានាថា មេធាវីអាចបំពេញមុខងារវិជ្ជាជីវៈរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបង្អាក់ ការយាយី ឬការជ្រៀតជ្រែកដែលមិនសមរម្យ រួចផុតពីការគំរាមចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀត ។

៣៨.	គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ក្នុងឆ្នាំ១៩៩៥ ដើម្បីធ្វើនិយតកម្មវិជ្ជា ជីវៈច្បាប់ថាជា "វិជ្ជាជីវៈមួយឯករាជ្យនិងស្វយ័ត" ។ ទោះជាយ៉ាងណាក៏ដោយ ឯករាជ្យភាពនៃគណៈមេធាវី ត្រូវបានមើលឃើញជាទូទៅថា ត្រូវបានសម្រុះសម្រួលនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មី១នេះ ។ ការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវីបានក្លាយទៅជារឿងនយោបាយមួយយ៉ាងធំ ។ ការតែងតាំងនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីមួយចំនួនជាសមាជិកគណៈមេធាវីក្នុងឆ្នាំ២០០៤ និងឆ្នាំ២០០៦ បើទោះជាមន្ត្រីទាំងនោះ

មិនមានគុណសម្បត្តិផ្នែកច្បាប់គ្រប់គ្រាន់តាមការទាមទារក៏ដោយ បានធ្វើឱ្យខូចដល់កេរ្តិ៍ឈ្មោះ និងបូរណភាពរបស់គណៈមេធាវីថាជាស្ថាប័នមួយឯករាជ្យ ។

៣៩. ការបោះឆ្នោតក្នុងខែតុលា ឆ្នាំ២០០៦ បានបញ្ចប់ជំលោះអំពីតំណែងប្រធាន ដែលបានបង្អាក់គណៈមេធាវីអស់រយៈពេលពីរឆ្នាំ ដោយមានការគាំទ្រដល់ប្រធានស្តីទី ដែលត្រូវបានយល់ឃើញជាទូទៅថាជាបេក្ខជនរបស់រដ្ឋាភិបាល ។ ជំហរដ៏តឹងតែងរបស់ប្រធានគណៈមេធាវី ពាក់ព័ន្ធនឹងការបង្កើត និងតួនាទីរបស់ការិយាល័យការពារក្តី នៅក្នុងអង្គជំនុំជំរះវិសាមញ្ញសំរាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហម បានធ្វើឱ្យមានកង្វល់ជាថ្មីថា គណៈមេធាវីមិនឯករាជ្យ និងមិនបំរើឧត្តមប្រយោជន៍របស់មេធាវីទាំងអស់ ដោយមិនគិតពីនិន្នាការនយោបាយរបស់ខ្លួន ។ លោកតំណាងពិសេស ក៏មានកង្វល់ផងដែរ អំពីការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌពីបទក្លែងបន្លំលិខិតស្នាមដែលស្ថិតក្នុងការមន្ទិលសង្ស័យជាខ្លាំង ដែលបទល្មើសនេះត្រូវជាប់ពន្ធនាគាររហូតដល់ ១៥ឆ្នាំ នៅតែកំពុងចាត់ការនៅឡើយ ប្រឆាំងនឹងអតីតសមាជិកក្រុមប្រឹក្សាមេធាវីមួយចំនួនធំ ដែលបានតវ៉ាអំពីការធ្វើនយោបាយភាវូបនីយកម្មនៃវិជ្ជាជីវៈមេធាវី ។

៤០. ការខ្វះឯករាជ្យភាព និងបូរណភាពនៃប្រព័ន្ធតុលាការ អាជ្ញាធរអយ្យការ និងវិជ្ជាជីវៈមេធាវី បង្ករឱ្យមានការគំរាមកំហែងខ្លាំងដល់សិទ្ធិមនុស្ស ។ រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលមានអភ័យឯកសិទ្ធិច្រើន ក្នុងការរំលោភច្បាប់ ចំណែកឯប្រជាជនស្លូតត្រង់ ដោយសារការញុះញង់ពីរដ្ឋាភិបាល បានក្លាយជាជនរងគ្រោះនៃប្រព័ន្ធច្បាប់ ។ ដូច្នេះប្រព័ន្ធច្បាប់នេះ មិនត្រឹមតែនៅឆ្ងាយពីការការពារសិទ្ធិមនុស្សទេ តែបែរជាក្លាយទៅជាស្ថាប័នចំបងមួយនៃការកៀបសង្កត់ទៅវិញ ។

## III. សិទ្ធិការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តក្នុងការសំដែងមតិ សិទ្ធិបង្កើតសមាគម និងសិទ្ធិជួបប្រជុំ

៤១. កិច្ចព្រមព្រៀងសន្តិភាពធានាការពារសិទ្ធិប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីអនុវត្តសកម្មភាពលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ។ នៅក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ ប្រជាពលរដ្ឋកម្ពុជា ទោះជាបុគ្គលក្តី និងចូលជាសមាគមជាមួយអ្នកដទៃក្តី បានខិតខំធ្វើការអស់ពីកំលាំងកាយចិត្ត ដើម្បីសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់គ្នា និងដើម្បីសិទ្ធិជាក់លាក់សំរាប់ស្ត្រី កុមារ កម្មករ ជនពិការ ជនភាគតិច និងអ្នកដទៃទៀត ។

៤២. ទន្ទឹងនឹងរដ្ឋាភិបាលទទួលបានការគាំទ្រជាទូទៅក្នុងសកម្មភាពអប់រំ ក៏មានការប្រយ័ត្នប្រយែងក្នុងការតស៊ូមតិដែរ ហើយជាទូទៅរដ្ឋាភិបាលបានប្រតិកម្មភ្លាមៗ ចំពោះសកម្មភាពទាំងឡាយណា ដែលតិះទៀនពីគោលនយោបាយ និង ការអនុវត្តន៍របស់ខ្លួន ។ រដ្ឋាភិបាលធ្លាប់ធ្វើជាសត្រូវរបស់អង្គការទាំងឡាយណាដែលការពារ តស៊ូមតិ និងឃ្លាំមើល

សិទ្ធិមនុស្ស ។ សមាជិកនៃអង្គការទាំងនេះ បានជួបប្រទះជារឿយៗនូវការបង្កាច់បង្ខូចពីមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីយុត្តិធម៌ ហើយផ្នែកខាងអាជ្ញាធររដ្ឋ ការរារែកទទួលយកការទទួលខុសត្រូវ ការបដិសេធទំនងជាស្រពិចស្រពិលដោយសារភាព យឺតយ៉ាវ និងភាពមិនច្បាស់លាស់ និងការរំពឹងថាបទល្មើសត្រូវបានបំភ្លេចចោល ។

៤៣. ការអភិវឌ្ឍន៍ប្រព័ន្ធសារព័ត៌មាន សំខាន់សំរាប់សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ ត្រូវបានប៉ះពាល់ជាអវិជ្ជមាននៅក្នុងប្រទេសកម្ពុជា ដោយអំពើឃាតកម្មដែលមិនអាចដោះស្រាយបានលើអ្នកកាសែត ការគំរាមកំហែងលើនិពន្ធនាយក និងការវាយប្រហារលើការិយាល័យអ្នកកាសែត ។ ទោះបីជាច្បាប់ស្តីពីរបបសារព័ត៌មានខែកក្កដាឆ្នាំ១៩៩៥ មានបញ្ញត្តិវិជ្ជមានមួយចំនួនក្តី ច្បាប់នេះហាមប្រាមដោយផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញ និងបទដ្ឋានអន្តរជាតិ "ការជេរប្រមាថដល់ស្ថាប័នជាតិ" និងមានអំណាចផ្អាកការបោះពុម្ពផ្សាយ និងការដាក់ពន្ធនាគារដល់អ្នកកាសែតចំពោះការបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែល "អាចបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ" ។

៤៤. ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាភាគច្រើននៃអង្គការពលកម្មអន្តរជាតិ ។ ទោះជាយ៉ាងណាក៏ដោយសហជីពខ្លះ នៅតែជួបប្រទះការលំបាកជាច្រើនក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន ហើយចាប់ពីមានកុបកម្មប្រឆាំងថៃកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ មក ការស្នើសុំធ្វើបាតុកម្មត្រូវបានបដិសេធជានិច្ចកាល ។ នគរបាលបន្តបំបែកការហែរក្បួន និងការធ្វើបាតុកម្ម ដោយសំអាងលើសណ្តាប់ធ្នាប់សាធារណៈ ។ ឃាតកម្មក្នុងឆ្នាំ២០០៤ លើលោកជា វិជ្ជា និង លោករស់ សុវណ្ណារ៉េត នៃសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់បានដោះស្រាយនៅឡើយ ដែលនាំឱ្យសហជីពកម្មករមានការភ័យខ្លាចក្នុងការធ្វើសកម្មភាពផ្សេងៗ ។

៤៥. ដើម្បីចូលរួមប្រកបដោយអត្ថន័យ និងមានប្រសិទ្ធភាព ក្នុងជីវភាពសាធារណៈនិងនយោបាយ ប្រជាពលរដ្ឋកម្ពុជា ត្រូវតែអាចរៀបចំ និងបង្កើតជាសមាគមជាមួយអ្នកដទៃ ហើយសំដែងមតិជាសមូហភាព បញ្ចេញទស្សនៈផ្ទាល់ខ្លួនដោយសេរី ស្វែងរកទទួល និងចែករំលែកព័ត៌មាន និងមតិយោបល់គ្រប់បែបយ៉ាងនៅក្នុងបរិយាកាសមួយដែលគ្មានអំពើហឹង្សា ការគាបសង្កត់ ឬការគំរាមកំហែង និងទទួលបានកេរ្តិ៍ជាមូលដ្ឋាននៃសន្តិសុខសេដ្ឋកិច្ច និងសុខុមាលភាព ។

៤៦. ពាក់ព័ន្ធនឹងសេរីភាពក្នុងការសំដែងមតិ លោកតំណាងពិសេសមានការសោកស្តាយថា អនុសាសន៍របស់លោកដាក់ជូនរដ្ឋាភិបាលស្នើឱ្យផ្អាក ឬលុបចោលបញ្ញត្តិស្តីពីការបរិហារកេរ្តិ៍ ការផ្សព្វផ្សាយព័ត៌មានមិនពិត និងការញុះញង់នៅក្នុងច្បាប់អ៊ុនតាក់ មិនត្រូវបានទទួលយកឡើយ ។ មាត្រា៦៣ នៃច្បាប់នេះ ចែងពីការបរិហារកេរ្តិ៍ ត្រូវបានធ្វើវិសោធនកម្មក្នុងខែឧសភា ឆ្នាំ២០០៦ ដើម្បីដកទោសគុកចេញពីការបរិហារកេរ្តិ៍ ប៉ុន្តែនៅតែអាចផាកពិន័យយ៉ាងធ្ងន់ធ្ងរ

ដដែល ។ ការបរិហារកេរ្តិ៍មានចែងនៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ។ ទោះជាគ្មានសេចក្តីរាយការណ៍ថា មានករណីបរិហារកេរ្តិ៍ថ្មីៗទៀតកើតមានបន្ទាប់ពីការធ្វើវិសោធនកម្មក៏ដោយ រដ្ឋាភិបាលបានប្រើជំនួសវិញនូវបញ្ញត្តិស្តីពី " ការផ្សាយព័ត៌មានមិនពិត " ជាបទល្មើសមួយដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ ហើយអនុញ្ញាតឱ្យឃុំខ្លួនជាបណ្តោះអាសន្នរង់ចាំការជំនុំជំរះ ។ បទល្មើសនេះក៏ត្រូវពិន័យជាប្រាក់យ៉ាងច្រើនផងដែរ ។

៤៧. តាមមាត្រា៦២ នៃច្បាប់អ៊ុនតាក់ ការផ្សាយព័ត៌មានមិនពិតកើតឡើងពេលដែល " នាយក ឬភាគីដទៃទៀតដែលទទួលខុសត្រូវលើការបោះពុម្ពផ្សាយ ឬលើមធ្យោបាយផ្សេងទៀតនៃគមនាគមន៍ដែលបានសំរេចចុះផ្សាយឬផ្សាយបន្តតាមមធ្យោបាយណាក៏ដោយ នូវព័ត៌មានមិនពិត ប្រឌិត ក្លែងក្លាយ ឬដោយកុហកទំលាក់កំហុសដោយអសុទ្ធចិត្តទៅលើជនទីបី ដោយគំនិតព្យាបាទ ត្រូវចាត់ទុកថា ការបោះពុម្ពផ្សាយ ការផ្សព្វផ្សាយ ឬការផ្សាយបន្តនោះបានរំខាន ឬអាចរំខានដល់សន្តិសុខសាធារណៈ" ។ បទល្មើសនេះទាមទារឱ្យមានបទដ្ឋានមួយខ្ពស់នៃការបង្ហាញភស្តុតាងសំរាប់ការផ្តន្ទាទោសបានៈ ព័ត៌មានត្រូវតែជាព័ត៌មានមិនពិត ឬប្រឌិត ឬកុហក ការបោះពុម្ពផ្សាយត្រូវតែជាការផ្សាយដោយអសុទ្ធចិត្ត ដោយគំនិតព្យាបាទ ហើយការបោះពុម្ពផ្សាយនេះទៀតសោធ ត្រូវតែជាការផ្សាយដែលបានបណ្តាលឬអាចនឹងបណ្តាលឱ្យកើតមានការរំលោភដល់សន្តិសុខសាធារណៈ ។

៤៨. ករណីពីរខាងក្រោមនេះ បង្ហាញពីកង្វល់របស់លោកតំណាងពិសេស ។ ឧបនាយករដ្ឋមន្រ្តីសុខ អាន បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងនិពន្ធនាយកនៃកាសែត *មនសិការ* ចំពោះការផ្សាយអត្ថបទមួយ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ ដែលបានរាយការណ៍ពីភាពតានតឹងរវាងសមាជិកគណបក្សប្រជាជនកម្ពុជានិងរដ្ឋមន្រ្តីរូបនេះ ដោយសារអំពើពុករលួយ និងការក្តោបអំណាចនៅក្នុងដៃរបស់ខ្លួន ។ ករណីនេះត្រូវបានជំនុំជំរះ នៅថ្ងៃទី១៥ ខែកញ្ញា ។ និពន្ធនាយក និងមេធាវី របស់គាត់មិនបានបង្ហាញខ្លួននៅតុលាការទេ ។ តុលាការបានរកឃើញថា និពន្ធនាយករូបនេះមានពិរុទ្ធភាពពីបទផ្សាយព័ត៌មានមិនពិត ហើយបានកាត់ទោសឱ្យគាត់បង់ប្រាក់ពិន័យចំនួនប្រមាណជា ២.០០០ដុល្លាដល់រដ្ឋ និងប្រាក់ប្រមាណ ជា ២.៥០០ដុល្លាទៀត ដល់លោករដ្ឋមន្រ្តី សុខ អាន ។ ក្នុងករណីនេះ ចៅក្រមបានចាត់ទុកថាអត្ថបទកាសែតនេះ គឺជាភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើការផ្តន្ទាទោសពីបទផ្សាយព័ត៌មានមិនពិត ។

៤៩. លោកទៀង ណារិទ្ធ គ្រូបង្រៀនច្បាប់ និងវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យពុទ្ធិកៈព្រះសីហនុរាជ្យនៅរាជធានីភ្នំពេញ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៦ ហើយត្រូវបានចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ពាក់ព័ន្ធនឹងសៀវភៅ "ទស្សនៈវិជ្ជានយោបាយ" របស់គាត់ ដែលបានសរសេររិះគន់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ។ បច្ចុប្បន្ន លោកទៀង ណារិទ្ធ កំពុងជាប់ឃុំឃាំងរងចាំការជំនុំជំរះ ។ មានរបាយការណ៍អាចឱ្យជឿបានថាគាត់មានជម្ងឺសរសៃប្រសាទ ហើយសុខុមាលភាពរបស់គាត់គឺជាកង្វល់មួយខ្លាំងបំផុត ។ គាត់ត្រូវការការថែទាំ និងការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ ហើយត្រូវតែដោះលែងគាត់ជាបន្ទាន់ ។

៥០. ក្នុងខែសីហា ឆ្នាំ២០០៦ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីលក្ខន្តិកៈសមាជិករដ្ឋសភា ដោយដាក់សមាជិករដ្ឋសភាឱ្យប្រឈមមុខនឹងហានិភ័យកាន់តែធ្ងន់ធ្ងរ ។ ដោយមានបទបញ្ញត្តិ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ក៏ដូចជាផ្ទុយនឹងបទដ្ឋានអន្តរជាតិ ច្បាប់នេះដាក់កំហិតដល់អភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងការគោរពដល់សេរីភាពនៃការសំដែងមតិ ។ ច្បាប់នេះ ដាក់សមាជិកសភាទាំងឡាយណាដែលយោបល់របស់ខ្លួនហាក់ដូចជាបំពានលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ទំនៀមទំលាប់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ ឱ្យស្ថិតនៅក្រោមទោសទណ្ឌដូចគ្នានឹងទោសទណ្ឌដែលមានរួចហើយ ចំពោះការដាក់កំហិតដល់សេរីភាពនៃការសំដែងមតិ របស់ប្រជាពលរដ្ឋកម្ពុជាទូទៅ ។ ច្បាប់ដដែលនេះអនុញ្ញាតឱ្យមានការចាប់ខ្លួនសមាជិកសភា ដោយមិនចាំបាច់ដកអភ័យឯកសិទ្ធិជាមុនឡើយ ។ ក្នុងពេលដែលលោកសរសេរបញ្ចប់របាយការណ៍របស់លោក លោកតំណាងពិសេសបានទទួលដំណឹងថារដ្ឋសភាបានធ្វើវិសោធនកម្មមាត្រា១២០ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ កាលពីថ្ងៃទី១៥ ខែធ្នូ ដែលតាមរយៈច្បាប់នេះ សមាជិកសភាដែលត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ នឹងត្រូវបាត់បង់អាសនៈរបស់ខ្លួនដោយស្វ័យប្រវត្តិ ។

៥១. មាត្រា៣៧ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ ធានាការពារសិទ្ធិធ្វើកូដកម្មបាតុកម្មដោយសន្តិវិធី និងសេរីភាពនៃការប្រមូលផ្តុំ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានបន្តរិតត្បិតសិទ្ធិទាំងនេះក្នុងឆ្នាំ២០០៦ តាមរយៈការបដិសេធតាមទំនើងចិត្ត និងជាប្រចាំចំពោះការស្នើសុំធ្វើបាតុកម្ម និងការប្រមូលផ្តុំជាសាធារណៈ ។ សកម្មភាពរបស់អាជ្ញាធរចំពោះការប្រមូលផ្តុំជាសាធារណៈនៅតែជាការរិតត្បិតមួយ ជាជាងការជួយសំរួល ។ នៅទីណាដែលការធ្វើបាតុកម្ម ឬការប្រមូលផ្តុំ បានធ្វើឡើងដោយគ្មានការអនុញ្ញាត ការប្រើកំលាំងលើសលុប និងមិនសមាមាត្រត្រូវបានកត់សំគាល់នៅក្នុងករណីជាច្រើន ដោយបច្ចុប្បន្ននេះ នគរបាលតែងកាន់និងប្រើប្រាស់ដំបងឆក់ជាប្រចាំទៀតផង ។

៥២. លោកតំណាងពិសេសមានកង្វល់ថា បាតុកម្មដែលកើតឡើងដោយខ្លួនឯង ត្រូវបានសន្មត់ជាទូទៅថាជាការគំរាមកំហែងដល់រដ្ឋាភិបាល ជាកិរិយាបទមួយដែលបង្ហាញតាមរយៈការសំរេចមិនអនុញ្ញាតឱ្យធ្វើបាតុកម្ម និងតាមរយៈសេចក្តីព្រាងច្បាប់ ដែលកំពុងតែរៀបរៀងដោយក្រសួងមហាផ្ទៃ ដើម្បីបញ្ញត្តពីការប្រមូលផ្តុំ ។ ចំណុចចាប់ផ្តើមច្បាស់លាស់នៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ចំពោះសេចក្តីព្រាងច្បាប់ស្តីពីសេរីភាពនៃការប្រមូលផ្តុំ និងការធ្វើបាតុកម្មដោយសន្តិវិធីហាក់ដូចជាដាក់ការរិតត្បិត ជាជាងផ្តល់សេរីភាព ដែលស្ថិតនៅក្រោមក្របខ័ណ្ឌបទបញ្ញត្តមួយសមរម្យ ។ រដ្ឋាភិបាលក៏បានបង្ហាញពីចំណូលចិត្តរបស់ខ្លួន ចំពោះការអនុវត្តន៍សេរីភាពនៃការប្រមូលផ្តុំជាអសាធារណៈ នៅក្នុងបរិវេណឯកជន ។

៥៣. ច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល ត្រូវបានដាក់ក្នុងរបៀបវារៈរបស់រដ្ឋាភិបាល តាំងពីឆ្នាំ១៩៩៥ មកម្លេះ ។ រដ្ឋាភិបាលបានអះអាងថា មាត្រា៤២នៃរដ្ឋធម្មនុញ្ញតម្រូវឱ្យខ្លួនព្រាងច្បាប់មួយ ។ មាត្រា៤២ចែងថាប្រជាពលរដ្ឋខ្មែរ

មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។ មាត្រានេះក៏ចែងផងដែរថា ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។ ដូចបានកត់សំគាល់នៅក្នុងរបាយការណ៍កន្លងមករបស់លោកតំណាងពិសេសនៅក្នុងឆ្នាំ២០០៥ ក្រសួងមហាផ្ទៃបានស្នើសុំធនាគារពិភពលោក ជួយព្រាងច្បាប់នេះ ។ បើតាមទស្សនៈរបស់ធនាគារពិភពលោក គេមិនចាំបាច់មានច្បាប់នេះទេ ហើយធនាគារពិភពលោកបានស្នើឱ្យមានការពិភាក្សាគ្នាមួយ រវាងអង្គការក្រៅរដ្ឋាភិបាលនិងរដ្ឋាភិបាលដើម្បីកំណត់បញ្ហាផ្សេងៗដែលភាគីនីមួយៗជួបប្រទះ ។ អង្គការសិទ្ធិមនុស្ស និងតស៊ូមតិនានានៅតែអំពល់ពីបំណងរបស់រដ្ឋាភិបាល ព្រួយបារម្ភថាចេតនារបស់រដ្ឋាភិបាល គឺដើម្បីរឹតត្បិត ជាជាងជួយសំរួលដល់សកម្មភាពរបស់ពួកគេ ។

៥៤. វានឹងមានសារៈសំខាន់ចំពោះការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ខាងមុខ ត្រូវធ្វើឡើងក្នុងបរិយាកាសមួយគ្មានការភ័យខ្លាចដែលសេរីភាពជាសារវន្ត ត្រូវបានគោរពនិងលើកស្ទួយយ៉ាងពេញលេញ ។ ទាំងនេះនឹងក្លាយជាការបោះឆ្នោតលើកដំបូង បន្ទាប់ពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ខែមីនា ឆ្នាំ២០០៦ ដើម្បីបន្ថយចំនួនតំណាងរាស្ត្រសំរាប់បង្កើតរដ្ឋាភិបាល ដែលតំរូវពីចំនួន២/៣ មកចំនួន៥០ +១ វិញ ។

៥៥. លោកតំណាងពិសេសមុនបានរាយការណ៍អំពីឃាតកម្មចំនួន៤៣ករណី ក្នុងកំឡុងពេលបោះឆ្នោតចុងក្រោយគេដែលករណីទាំងនេះត្រូវបានសង្ស័យខ្លាំងថាជារឿងនយោបាយ ។ ករណីភាគច្រើនទាក់ទងនឹងសមាជិកគណបក្សសមរង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច[២] ហើយករណីភាគច្រើននៅមិនទាន់បានដោះស្រាយគួរឱ្យជឿទុកចិត្តបានទេ ។ នៅក្នុងបរិបទនៃការបោះឆ្នោតខាងមុខនេះ រដ្ឋាភិបាលត្រូវចាត់វិធានការហើយត្រូវតែជាវិធានការជាក់ស្តែង ក្នុងការការពារឱ្យមានប្រសិទ្ធិភាព ដើម្បីធានាជាថ្មីដល់ប្រជាពលរដ្ឋកម្ពុជា ពីសុវត្ថិភាពរបស់គេ ហើយត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់រាល់ករណីឃាតកម្ម ការគំរាមកំហែង និងការបំភិតបំភ័យធ្ងន់ធ្ងរប្រឆាំងនឹងសកម្មជននយោបាយ ។ អាជ្ញាធរបោះឆ្នោតមិនគួរដោះស្រាយបណ្តឹងទាំងឡាយដែលទាក់ទងនឹងការរំលោភច្បាប់ព្រហ្មទណ្ឌឡើយ ។

[២] ហ៊្វុនស៊ិនប៉ិច " *Funcinpec* " ជាពាក្យបំព្រួញពីភាសាបារាំង “Front Uni National pour un Cambodge Indépendant, Neutre, Pacifique, et Coopératif ” ឬជាភាសាអង់គ្លេស "National United Front for an Independent, Neutral, Peaceful, and Cooperative Cambodia".

## IV. និទណ្ឌភាព និងការទទួលខុសត្រូវ

៥៦. កិច្ចព្រមព្រៀងសន្តិភាពបានចែងថា ប្រវត្តិសាស្ត្រសោកនាដកម្ម នៃប្រទេសកម្ពុជាទាមទារឱ្យមានការចាត់វិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស និងការមិនវិលត្រឡប់មកវិញនៃគោលនយោបាយ និងការអនុវត្តន៍ពីអតីតកាល ។ របាយការណ៍មួយរបស់លោកតំណាងពិសេសមុន ចុះខែតុលា ឆ្នាំ២០០៥[៣] បង្ហាញថា ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ភាគច្រើនលើសលប់នៃឃាតកម្មជាច្រើនលើអ្នកនយោបាយ អ្នកកាសែត សហជីពកម្មករ និងប្រជាពលរដ្ឋកម្ពុជាដទៃទៀត ដែលសកម្មនៅក្នុងជីវភាពនយោបាយ និងសាធារណៈ នៅតែមិនទាន់ត្រូវបានដោះស្រាយនៅឡើយ ក្នុងនោះរួមមានករណីស៊ីឃ្លួលសំលាប់លោកជា វិជ្ជា ប្រធានសហជីពកម្មករ នៅកណ្តាលរាជធានីភ្នំពេញ ក្នុងខែមករា ឆ្នាំ២០០៤ផង ។ ក្នុងករណីនេះ បុរសពីរនាក់ដែលត្រូវបានជឿជាក់យ៉ាងទូលំទូលាយថាជាជនស្លូតត្រង់ ត្រូវបានចាប់ខ្លួនភ្លាមៗ ហើយត្រូវបានផ្តន្ទាទោសពីឃាតកម្មនេះ កាលពីខែសីហា ឆ្នាំ២០០៥ ។ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៦ សាលាឧទ្ធរណ៍ បានលើកពេលសវនាការភ្លាម ដោយមូលហេតុថាមានចៅក្រមម្នាក់ឈឺភ្លាមៗនោះ ។ កាលបរិច្ឆេទសំរាប់ការបើកសវនាការលើរឿងក្តីនេះ នៅមិនទាន់បានកំណត់ជាថ្មីនៅឡើយ ។

៥៧. និទណ្ឌភាពមានន័យថា ប្រជាពលរដ្ឋកម្ពុជា មិនត្រូវបានការពារដោយច្បាប់ទេ ។ ដូចរបាយការណ៍បញ្ជាក់ស្រាប់ និទណ្ឌភាពកើតមាននៅពេលដែលបុគ្គលទាំងឡាយដែលបំពានច្បាប់ និងប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សត្រូវបានរួចផុត ពីការផ្តន្ទាទោសណាមួយ ហើយមិនត្រូវបាននាំខ្លួនមកឱ្យទទួលខុសត្រូវតាមនីតិវិធីណាមួយ ទោះជាតាមនីតិវិធីព្រហ្មទណ្ឌ រដ្ឋប្បវេណី រដ្ឋបាល ឬខាងវិន័យ ឬដាក់ឱ្យទទួលទោសទណ្ឌណាមួយ ហើយគ្មានការជួសជុលសំណងដល់ជនរងគ្រោះនោះទេ ។ បើមាននិទណ្ឌភាព គឺគ្មានការការពារសិទ្ធិមនុស្សទេ ។ និទណ្ឌភាពគឺជាការផ្ទុយគ្នានឹងការទទួលខុសត្រូវនិងប្រតិនិក្ខេបបទនៃនីតិរដ្ឋ ។

៥៨. និទណ្ឌភាពចំពោះការរំលោភធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស មិនត្រឹមតែប៉ះពាល់ដោយផ្ទាល់ដល់ជនរងគ្រោះប៉ុណ្ណោះទេ ។ ដូចការកត់សំគាល់ក្នុងរបាយការណ៍នេះ នៅពេលដែលសកម្មជនគណបក្ស ត្រូវបានសំលាប់នៅមុនពេលបោះឆ្នោត វាមានផលប៉ះពាល់ដល់សេរីភាពក្នុងដំណើរការលិទ្ធិប្រជាធិបតេយ្យ ។ នៅពេលដែលអ្នកកាសែត ឬនិពន្ធនាយក ត្រូវបានធ្វើឃាត ឬការិយាល័យសារព័ត៌មានមួយត្រូវបានវាយប្រហារ នេះជាការក៏រិតដល់សេរីភាពខាងសារព័ត៌មាន និងសេរីភាពនៃការសំដែងមតិ ។ នៅពេលដែលនរណាម្នាក់ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌនៃការជួញដូរមនុស្ស

---

[៣] របាយការណ៍នេះ មានចំណងជើងថា " លំនាំនៃបញ្ហានិទណ្ឌភាពដែលកំពុងកើតមានជាបន្តនៅក្នុងប្រទេសកម្ពុជា " ដែលអាចរកឃើញតាមគេហទំព័រ: http://cambodia.ohchr.org/download.aspx?ep_id=242

សូកប៉ាន់ ព្រះរាជអាជ្ញា ឬចៅក្រម ឱ្យលើកលែងការចោទប្រកាន់ មានន័យថាតុលាការឈប់រវីរវល់ចំពោះអំពើល្មើសនោះ ។ នៅពេលដែលនគរបាលញុះញង់ ឬជួយសំរួលដល់ការសំលាប់ដោយហ្វូងមនុស្ស ហើយមិនត្រូវបានដាក់ទណ្ឌកម្មណាមួយនោះទេនោះពួកគេក្លាយជាអ្នកឃុបឃិតនៅក្នុងបទឧក្រិដ្ឋនេះ ។ នៅពេលដែលប្រធានសហជីពម្នាក់ត្រូវបានសំលាប់ ហើយអ្នកដែលទទួលខុសត្រូវនៅតែរត់គេចខ្លួន នេះជាការគំរាមកំហែងយ៉ាងធំដល់សិទ្ធិការងារ និងសេរីភាពខាងសមាគម ។ វាក៏ជានិទណ្ឌភាពផងដែរ បើអំពើពុករលួយមិនត្រូវបានត្រួតពិនិត្យ ឬប្រភពឱសថដែលក្រខ្សត់ត្រូវបានបន្លែបន្លំយកពីសេចក្តីត្រូវការបំផុត ដោយគ្មានការគ្រប់គ្រង និងការទទួលខុសត្រូវ ឬនៅពេលដែលដីធ្លីទទួលបានដោយការរំលោភច្បាប់ និងបានមកពីការដកហូតយកកម្មសិទ្ធិដីធ្លីពីប្រជាជននៅតាមជនបទ និងធ្វើឱ្យមានការបាត់បង់ជិវភាពរស់នៅជាមូលដ្ឋានរបស់ប្រជាជន ។

៥៩. របាយការណ៏នេះក៏បានកត់សំគាល់ដែរថា និទណ្ឌភាពមានផលប៉ះពាល់ផ្សេងទៀតដែលមានរយៈពេលយូរអង្វែង ព្រោះថាវាបណ្តោយឱ្យមន្ត្រីរាជការរំលោភច្បាប់ ដើម្បីការមានបានរបស់បុគ្គល ឬដើម្បីរក្សាបានប្រយោជន៏ដែលផ្តល់ឱ្យដោយការប្រតិបត្តក្រៅច្បាប់ ។ និទណ្ឌភាពក៏នាំឱ្យមានការលៃបំរុងដោយបំភ្លើសនូវធនធានសេដ្ឋកិច្ចធ្វើឱ្យធ្លាក់ដុនដាបថែមទៀតដល់វិសមភាពដែលមានស្រាប់ និងនាំឱ្យមានភាពក្រីក្រតទៅទៀត ។

៦០. រដ្ឋាភិបាលត្រូវចាត់វិធានការ ហើយត្រូវតែជាវិធានការជាក់ស្តែង ដ៏មានប្រសិទ្ធភាព ដើម្បីបញ្ចប់និទណ្ឌភាព ។ នៅក្នុងបរិបទនេះ អង្គជំនុំជំរះវិសាមញ្ញ តំណាងឱ្យក្តីសង្ឃឹមមួយ ដែលមិនត្រូវឱ្យកន្លងផុតឡើយ ចំពោះការទម្លុះទម្លាយលំនាំនៃនិទណ្ឌភាព ដែលបានចង្អុលប្រាប់ពីលក្ខណៈប្រវត្តិសាស្ត្រកម្ពុជាក្នុងទសវត្សរ៏ថ្មីៗនេះ ។

## V. ការស្តារនីតិសម្បទា និងការស្ថាបនាប្រទេសកម្ពុជាឡើងវិញ ដោយមានការគោរពយ៉ាងពេញលេញដល់សិទ្ធិមនុស្សសំរាប់ទាំងអស់គ្នា

៦១. សេចក្តីប្រកាសស្តីពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញ ដែលជាផ្នែកមួយនៃកិច្ចប្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានចែងថា គោលដៅចម្បងនៃការកសាងប្រទេសកម្ពុជាឡើងវិញ គួរតែជា "វឌ្ឍនភាពនៃប្រជាជន និងប្រជាជាតិកម្ពុជាដោយគ្មានការរើសអើងឬការប្រកាន់ពូជសាសន៏ និងដោយការគោរពយ៉ាងពេញលេញដល់សិទ្ធិមនុស្ស និងសេរីភាពជាសារវន្តសំរាប់ទាំងអស់គ្នា" ។ សេចក្តីប្រកាសនេះ ក៏បានចែងដែរថា ជំនួយសេដ្ឋកិច្ចគួរតែផ្តល់ប្រយោជន៏ ដល់គ្រប់តំបន់នៃប្រទេសកម្ពុជា ជាពិសេសតំបន់ដែលក្រីក្រជាងគេ ហើយគួរតែជ្រួតជ្រាបដល់គ្រប់ស្រទាប់សង្គមទាំងមូល ។ កិច្ចព្រមព្រៀងសន្តិភាព បានទទួលស្គាល់ពីសារៈសំខាន់នៃសិទ្ធិមនុស្ស ក្នុងការលើកស្ទួយដល់ការអភិវឌ្ឍន៏ប្រកបដោយសមភាព និងចិរភាពក្នុងប្រទេសកម្ពុជា ។

៦២. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ គឺជាផែនការមេសំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា ហើយរាល់ជំនួយទ្វេភាគី និងពហុភាគី ត្រូវបានរំពឹងថាតំរៀបគ្នា និងស៊ីសង្វាក់គ្នាជាមួយគោលការណ៍និងអាទិភាពនៃផែនការយុទ្ធសាស្រ្តនេះ ។ ទន្ទឹមនឹងតម្រូវឱ្យរដ្ឋាភិបាលអនុវត្តគោលការណ៍សំខាន់ៗមួយចំនួន ដូចជាការចូលរួម ការមិនរើសអើង និងការទទួលខុសត្រូវ ផែនការនេះមិនបានដាក់បញ្ចូលវិធានការច្បាស់លាស់ផ្សេងៗ ដើម្បីប្រែក្លាយគោលការណ៍ទាំងនេះឱ្យទៅជាការអនុវត្តជាក់ស្តែងឡើយ ។ ផែនការនេះក៏មិនបានបញ្ជាក់ពីសារៈសំខាន់នៃសិទ្ធិមនុស្សក្នុងការកាត់បន្ថយភាពក្រីក្រ និងក្នុងការសំរេចទិសដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាដែរ ។ រដ្ឋាភិបាល និងដៃគូសហប្រតិបត្តការអភិវឌ្ឍន៍របស់ខ្លួន គួរដឹងពីមុខងារស្នូលនៃការការពារ និងការលើកស្ទួយសិទ្ធិមនុស្សដើម្បីធានាស្ថិរភាពនយោបាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។

៦៣. ទោះបីជាមួយទសវត្សរ៍កន្លងទៅនេះ មានការរីកចំរើនខាងសេដ្ឋកិច្ចនិងលំហូរចូលនៃជំនួយដ៏ច្រើនក៏ដោយ ក៏ការរីកចំរើននេះភាគច្រើនហុំព័ទ្ធតែតាមតំបន់ទីក្រុងប៉ុណ្ណោះ ។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើននៅផ្តុំជុំវិញបន្ទាត់នៃភាពក្រីក្រ ហើយត្រូវបានប៉ាន់ប្រមាណថា ៣៥% ស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រ ។ របាយការណ៍របស់ធនាគារពិភពលោកដែលមានចំណងជើងថា *ការវាយតំលៃពីភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៦* បានរកឃើញថា ទោះជាភាពក្រីក្រត្រូវបានកាត់បន្ថយក្តី ការបែងចែកភោគទ្រព្យដែលចេះតែកើនឡើង បង្ហាញពីគំលាតដ៏តក់ស្លុត និងដែលចេះតែរីកធំទៅៗ រវាងអ្នកមាននិងអ្នកក្រ ។ អ្នកដែលគ្មានដីធ្លីកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស ដោយសារតែកត្តាចំរុះមួយចំនួនរួមទាំងការចាប់យកដីធ្លីដោយខុសច្បាប់ ដែលបន្ទរដោយការធ្លាក់ចុះនៃសិទ្ធិទទួលបានការប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ។ របាយការណ៍នេះបានសន្និដ្ឋានថា ជាមួយនឹងនិន្នាការបច្ចុប្បន្ននេះ ប្រទេសកម្ពុជា នឹងមិនសំរេចទិសដៅអភិវឌ្ឍន៍សហសវត្សរ៍នៃការកាត់បន្ថយភាពក្រីក្រត្រឹមឆ្នាំ២០១៥បានឡើយ ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលជាវិទ្យាស្ថានស្រាវជ្រាវមួយនៅភ្នំពេញ ក៏បានសន្និដ្ឋានក្នុងការសិក្សាព្រាងថ្មីៗនេះថា មានភស្តុតាងតិចតួចណាស់ពីការកាត់បន្ថយជាដំកំភួននូវភាពក្រីក្រ វិសមភាព និងការដកហូតតំរូវការជាមូលដ្ឋានរបស់មនុស្ស ។

៦៤. លោកតំណាងពិសេសកត់សំគាល់ដោយក្តីកង្វល់ថា រដ្ឋាភិបាលមិនទាន់បានបញ្ជូនរបាយការណ៍ដំបូងរបស់កម្ពុជាពីការអនុវត្តន៍របស់ខ្លួនចំពោះកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលត្រូវបានដល់ពេលកំណត់តាំងពីឆ្នាំ១៩៩៤ នោះឡើយ ។ របាយការណ៍នេះ និងការពិចារណាលើរបាយការណ៍នេះ ដោយគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បង្ហាញពីឱកាសដ៏មានតំលៃមួយ ដើម្បីធ្វើសមាហរណកម្មជាក់ស្តែងសមិទ្ធិរីកចំរើននៃសិទ្ធិទាំងនេះរបស់កម្ពុជា ដែលមានចែងក្នុងកតិកាសញ្ញានេះ ទៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍

ជាតិ និងដើម្បីឱ្យរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ និងទីភ្នាក់ងារអន្តរជាតិនានា រួមគ្នាកំណត់ និងពិភាក្សាពីមធ្យោបាយផ្សេងៗ ដើម្បីជំនះឧបសគ្គដល់ការទទួលបានសិទ្ធិទាំងនេះ ។

## VI. សិទ្ធិប្រើប្រាស់ដីធ្លី និងការចិញ្ចឹមជីវិត

៦៥. ប្រជាពលរដ្ឋកម្ពុជាភាគច្រើនរស់នៅតំបន់ជនបទ ហើយពឹងផ្អែកទាំងស្រុកលើដីធ្លី និងធនធានធម្មជាតិ ដែលជាប្រភពសំរាប់ចិញ្ចឹមជីវិត ។ ដូច្នេះ បញ្ហាដែលថាតើប្រទេសកម្ពុជាគ្រប់គ្រង និងបែងចែកដីធ្លីនិងធនធានធម្មជាតិរបស់ខ្លួនរបៀបណា ហើយសំរាប់ជាប្រយោជន៍របស់អ្នកណា នេះជាបញ្ហាមួយធ្ងន់ធ្ងរក្នុងចំណោមបញ្ហាធំៗដទៃទៀត ដែល ប្រទេសកម្ពុជាកំពុងជួបប្រទះក្នុងពេលបច្ចុប្បន្ននេះ ។ វាជាការសំខាន់ផងដែរ ចំពោះលទ្ធភាពរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបត្រូវទទួលបានប្រយោជន៍ពីការអភិវឌ្ឍន៍ប្រកបដោយសមភាព និងចិរភាព ដែលគោរព និងលើកស្ទួយសិទ្ធិរបស់ខ្លួន ។

៦៦. ផ្ទុយនឹងគោលការណ៍ដែលមានចែងក្នុងសេចក្តីប្រកាសស្តីពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញ ប្រជា ពលរដ្ឋកម្ពុជានៅតំបន់ជនបទ មិនបានទទួលការការពារតាមផ្លូវច្បាប់ ដោយត្រូវបានគេជន្លៀសកាន់តែច្រើនឡើងៗ ចេញពីដីព្រៃ និងធនធានដទៃទៀត ដែលប្រជាពលរដ្ឋទាំងនោះភាគច្រើនពឹងអាស្រ័យ និងអាចទាមទារដោយស្របច្បាប់ ។ រដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិកម្មសិទ្ធិឯកជនលើដីធ្លី សិទ្ធិនេះឋិតនៅក្រោមការគាំពារនៃច្បាប់ ។ ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់មុនឆ្នាំ២០០១ មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធររដ្ឋាភិបាល ដែលទទួលខុសត្រូវក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាល បានជាប់ពាក់ព័ន្ធក្នុងការលក់ដីដោយខុសច្បាប់ ឬបង្ខិតបង្ខំឱ្យមានការលក់ដី ដែលធ្វើឱ្យសហគមន៍ជនបទនានា បាត់បង់ដីធ្លី និងប្រភពសំរាប់ចិញ្ចឹមជីវិត ។ ប្រព័ន្ធតុលាការបានលើកស្ទួយការជួញដូរដីធ្លីខុសច្បាប់ទាំងនេះ ដោយការមិនអនុវត្តតាមបទបញ្ញត្តិ ឬចេតនារបស់ច្បាប់ភូមិបាល ដែលនាំឱ្យប្រជាពលរដ្ឋនៅជនបទ បាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ ដែលជាមធ្យោបាយសំរាប់ធ្វើការទាមទារសិទ្ធិរបស់ខ្លួន និងផ្តល់ការដោះស្រាយ និងសំណងដ៏មានប្រសិទ្ធភាពនោះ ។

៦៧. លោកតំណាងពិសេសក៏បានសំដែងនូវកង្វល់ជាបន្ត អំពីការបណ្តេញប្រជាពលរដ្ឋក្រីក្រមិនឱ្យតាំងទីលំនៅតាមដងទន្លេបាសាក់ក្នុងរាជធានីភ្នំពេញ ហើយឱ្យទៅតាំងលំនៅថ្មីនៅតំបន់ដែលខ្វះហេដ្ឋារចនាសម្ព័ន្ធ និងសេវាមូលដ្ឋាននានា ដូចជា ទឹក អនាម័យ និងអគ្គីសនី ហើយដែលទីតាំងថ្មីទាំងនោះឋិតនៅឆ្ងាយពីរាជធានីភ្នំពេញ ដែលពួក

គេមិនអាចមានលទ្ធភាពប្រកបរបរចិញ្ចឹមជីវិតបាន ។ កង្វល់អំពីសភាពការណ៍នេះ ត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់លោកតំណាងពិសេស ការជូនដំណឹងទៅរដ្ឋាភិបាល និងក្នុងរបាយការណ៍លេខ (E/CN.4/2006/41/Add.3) របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ ។

## ក. សម្បទានដីសេដ្ឋកិច្ច តាមផ្លូវច្បាប់ និងតាមការអនុវត្តន៍ជាក់ស្តែង

៦៨. សម្បទានដីសេដ្ឋកិច្ច សំដៅដល់ចំការកសិ-ឧស្សាហកម្មទាំងឡាយដែលមានទ្រង់ទ្រាយធំ ដែលរដ្ឋាភិបាលបានផ្តល់ឱ្យ បុគ្គល ឬក្រុមហ៊ុនផ្សេងៗ ដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបង្កើនការងារនៅតំបន់ជនបទ ។ ថ្វីបើដូច្នេះក៏ដោយ របាយការណ៍របស់ធនាគារពិភពលោក ដែលមានចំណងជើងថា *ការវាយតំលៃពីភាពក្រីក្រនៅកម្ពុជា ឆ្នាំ ២០០៦* បានបង្ហាញឱ្យឃើញថា ផលិតផលកសិកម្មមានកំរិតទាប ។ ដើម្បីជំរុញការអភិវឌ្ឍន៍ និងសមភាព របាយការណ៍នេះបានផ្តល់អនុសាសន៍ ឱ្យធ្វើកសិកម្មជាទ្រង់ទ្រាយតូច ជាជាងគំរូបច្ចុប្បន្ននៃសម្បទានទ្រង់ទ្រាយធំ ឬកសិកម្ម ជាលក្ខណៈចំការធំៗ ។

៦៩. របាយការណ៍នេះបង្ហាញច្បាស់ថា សម្បទានដីសេដ្ឋកិច្ច មិនបានផ្តល់អត្ថប្រយោជន៍ជាក់ស្តែងដល់ប្រជាពលរដ្ឋនៅជនបទទេ ផ្ទុយទៅវិញវាបានធ្វើឱ្យសហគមន៍ជាច្រើនបាត់បង់ប្រភពសំខាន់ៗសំរាប់ចិញ្ចឹមជីវិត ធ្វើឱ្យស្ថានភាពដែលលំបាកស្រាប់រិតតែធ្លាក់ដុនដាប ឬលំបាកខ្លាំងឡើងថែមទៀត ។ របាយការណ៍នេះក៏បានបង្ហាញច្បាស់ដែរថា ការផ្តល់សម្បទានដីសេដ្ឋកិច្ចបានបង្កើនការក្តោបក្តាប់ទ្រព្យសម្បត្តិ និងធនធាននៅក្នុងដៃរបស់ជនមួយចំនួន ដែលមានឥទ្ធិពលខាងនយោបាយ ឬសេដ្ឋកិច្ច ។

៧០. លោកតំណាងពិសេស បានមានលទ្ធភាពសិក្សាលើច្បាប់ភូមិបាល ឆ្នាំ២០០១ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ដែលគណៈរដ្ឋមន្ត្រីបានអនុម័តក្នុងឆ្នាំ២០០៥ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋចែងថា ជាទូទៅរដ្ឋគឺជាម្ចាស់កម្មសិទ្ធិលើដីទាំងអស់ ដែលមិនមែនជាដីឯកជន ឬសមូហភាពស្របច្បាប់ ដែលមានចែងក្នុងច្បាប់ភូមិបាល ហើយនិងបែងចែកភាពខុសប្លែកគ្នារវាងដី "សាធារណៈរបស់រដ្ឋ " និង ដី "ឯកជនរបស់រដ្ឋ" ។ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចចែងថា សម្បទានដីសេដ្ឋកិច្ចអាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០ ( មួយម៉ឺនហិកតា) ហើយអាចផ្តល់បានចំពោះតែដីដែលបានចុះបញ្ជី និងបានធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ និងដោយត្រូវគោរពតាមលក្ខខណ្ឌវិនិច្ឆ័យដី ដែលមានផែនការប្រើប្រាស់ដីដែលបានអនុម័តរួច ការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ការពិគ្រោះយោបល់ជាសាធារណៈ ហើយក៏ត្រូវមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីផងដែរ ។ សម្បទានដីសេដ្ឋកិច្ចទាំងឡាយ ដែលបានផ្តល់នៅមុនអនុក្រឹត្យនេះ នឹងត្រូវត្រួតពិនិត្យឡើងវិញ លើការ

អនុវត្តន៍របស់សម្បទានិកផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យា ធ្វើការពិគ្រោះយោបល់ជាសាធារណៈដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ចនៅក្នុងឃុំសង្កាត់ដែលដីសម្បទាននោះស្ថិតនៅ និងធ្វើការចរចាលើការកាត់បន្ថយទំហំសម្បទានដីណាដែលលើសពី១០.០០០ ហិកតា។

៧១. នៅក្នុងការអនុវត្តន៍ជាក់ស្តែង គេមិនឃើញមានកិច្ចដំណើរជាប្រព័ន្ធ ដើម្បីកំណត់ការធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជីដីរដ្ឋ នៅមុនពេលផ្តល់សម្បទានដីសេដ្ឋកិច្ច ដូចដែលច្បាប់បានតំរូវនោះទេ។ បន្ទាប់ពីការអនុម័តអនុក្រឹត្យរួចហើយ នៅតែមានការបន្តផ្តល់សម្បទានដី នៅមុនពេលមានការកំណត់ថា ដីនោះពិតជាដីឯកជនរបស់រដ្ឋ ហើយមិនមែនជាដីដែលមានកម្មសិទ្ធ ឬកាន់កាប់ដោយឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាល។ ជាទូទៅដីភាគច្រើនដែលបានផ្តល់សម្បទាន មិនបានចុះបញ្ជី ឬធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋឡើយ។

៧២. ម្យ៉ាងវិញទៀត លក្ខខណ្ឌវិនិច្ឆ័យផ្សេងទៀត សំរាប់ការផ្តល់សម្បទានមិនទាន់បានបំពេញនៅឡើយទេ។ ក្នុងករណីមានការវាយតំលៃពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានធ្វើឡើងដើម្បីឱ្យស្របតាមការតម្រូវរបស់អនុក្រឹត្យនេះ បើតាមព័ត៌មានដែលអាចជឿទុកចិត្តបាន គឺការវាយតំលៃទាំងនេះ ជានិច្ចកាលមិនធ្វើឡើងដោយពិតប្រាកដ និងត្រឹមត្រូវទេ។

៧៣. ជាឧទាហរណ៍ លោកតំណាងពិសេសត្រូវបានជំរាបឱ្យដឹងថា ការវាយតំលៃពីហេតុប៉ះពាល់បរិស្ថាននៃសម្បទានដែលបានផ្តល់ក្នុងឆ្នាំ២០០៦ នៅស្រុកស្រែអំបិល ខេត្តកោះកុង បាននិយាយតែពីប្រភេទដីតែប៉ុណ្ណោះ។ គេមិនបានពិនិត្យទូទៅអំពីហេតុប៉ះពាល់បរិស្ថាន ឬហេតុប៉ះពាល់សង្គម ចំពោះសហគមន៍ទាំងឡាយដែលកំពុងរស់នៅ និងធ្វើកសិកម្មលើដី ដែលសម្បទានបានគ្រប់ដណ្តប់នោះទេ។ ការតម្រូវឱ្យមានការពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋមូលដ្ឋាន ជាទូទៅត្រូវបានគេមើលរំលងនៅមុនពេលសំរេចផ្តល់សម្បទានណាមួយ ហើយអាជ្ញាធរមូលដ្ឋាន មិនបានអនុវត្តតាមទេ។ សហគមន៍ជាច្រើនដែលរងផលប៉ះពាល់បានបញ្ជាក់ថា ពួកគេមិនបានដឹងពីគំរោងផ្តល់សម្បទាននោះទេ រហូតដល់ពេលឃើញក្រុមហ៊ុនមកដល់ចាប់ផ្តើមប្រតិបត្តិការ ហើយថាមិនមានការពិគ្រោះយោបល់បានធ្វើឡើងជាមួយពួកគេទេ ទោះបីជាពួកគេបានរស់នៅ និងធ្វើកសិកម្មលើដីនោះអស់រយៈពេលជាច្រើនឆ្នាំហើយក៏ដោយ។

៧៤. មិនមែនជាការភ្ញាក់ផ្អើលនោះទេ ដែលសម្បទានដី នៅតែបន្តផ្តល់ដោយគ្មានការពិគ្រោះយោបល់ត្រឹមត្រូវ ឬដោយគ្មានការគិតគូរអំពី កម្មសិទ្ធិ ភោគៈ និងការប្រើប្រាស់ដីដែលមានស្រាប់ ដែលសម្បទានទាំងនេះមានផល

ប៉ះពាល់ជាអវិជ្ជមានទៅលើសហគមន៍ដែលពាក់ព័ន្ធនានា ។ កង្វល់ជារួម និងមានដូចគ្នា ដែលបានរាយការណ៍ដោយសហគមន៍នានា រួមមានការរុករានទន្ទ្រានដីស្រែចំការរបស់ពួកគេដោយក្រុមហ៊ុនសម្បទាន ដែលនាំឱ្យមានការខ្វះខាតស្បៀងអាហារ បាត់បង់សិទ្ធិចូលព្រៃដើម្បីប្រមូលនិងលក់អនុផលព្រៃឈើ បាត់បង់វាលស្មៅសំរាប់ចិញ្ចឹមសត្វពាហនៈ ការកាប់ឈើខុសច្បាប់ ការគំរាមកំហែង និងការបំភិតបំភ័យពីសំណាក់កម្មករក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន ។

## ខ. តម្លាភាព និងការទទួលបានព័ត៌មាន

៧៥. បើតាមព័តិមានដែលទទួលបាន មានសម្បទានដីគោលដៅសេដ្ឋកិច្ចជាង៤០ ត្រូវបានផ្តល់ជាផ្លូវការក្នុងខេត្តចំនួន១៤ ។ ក្រៅពីនេះ មានព័តិមានអំពីសម្បទានថ្មីច្រើនទៀត ដែលអាចត្រូវបានផ្តល់ រួមទាំងនៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី កំពត និងឧត្តរមានជ័យ ។

៧៦. ទោះជាក្រសួងកសិកម្មបានចាត់វិធានការ ដើម្បីផ្សព្វផ្សាយព័តិមានតាមរយៈវិបសាយរបស់ក្រសួងក៏ដោយ ក៏ព័តិមានដែលបានផ្តល់នោះមិនគ្រប់គ្រាន់ឡើយ ហើយជារឿយៗគេមិនអាចបើកទំព័រវិបសាយបានទេ ។ បើតាមព័តិមានដែលទទួលបាន មានកិច្ចសន្យាសម្បទានតែមួយគត់ត្រូវបានមោឃៈភាព សម្បទាននោះត្រូវបានផ្តល់នៅក្នុងឆ្នាំ២000 ប៉ុន្តែមិនបានប្រើប្រាស់ទេ ។ មិនមានព័តិមានស្តីពីការពិនិត្យឡើងវិញតាមការចាំបាច់នៃសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់នៅមុនការអនុម័តច្បាប់ភូមិបាល និងការកាត់បន្ថយសម្បទានទាំងឡាយដែលមានទំហំលើសពី១0.000 ហិកតា ដូចមានចែងក្នុងច្បាប់នោះទេ ។

៧៧. សម្បទានក្រុមហ៊ុនភាពីម៉ិច ដែលលាតសន្ធឹងកាត់ខេត្តកំពង់ឆ្នាំង និងពោធិសាត់ ដែលបច្ចុប្បន្ន មិនមានសកម្មភាព ហើយដែលសម្បទាននោះមានផ្ទៃដីផ្លូវការច្រើនជាង ៣00.000 ហិកតា គឺមានទំហំ ៣0 ដងធំជាងទំហំដែលបានកំណត់នៅក្នុងច្បាប់ភូមិបាល ។ សម្បទានក្រុមហ៊ុនគ្រីនស៊ី ក្នុងខេត្តស្ទឹងត្រែង ដែលបានផ្តល់នៅក្នុងឆ្នាំ២00១ នៅមុនការអនុម័តច្បាប់ភូមិបាលបន្តិច ដែលមានផ្ទៃដីជាង ១00.000 ហិកតា ហើយមានសេចក្តីរាយការណ៍ថា ក្រុមហ៊ុននេះ បានចាប់ផ្តើមបើកការដ្ឋានហើយ ។ ការកាត់បន្ថយទំហំដីសម្បទានដែលមានស្រាប់មកនៅត្រឹម ១0.000 ហិកតា នឹង អាចផ្តល់ដីដែលកាត់ចេញនោះ សំរាប់សម្បទានដីសង្គមកិច្ចឱ្យដល់ប្រជាពលរដ្ឋក្រីក្របំផុត ដូចមានចែងនៅក្នុងច្បាប់ភូមិបាល ។

៧៨. លោកតំណាងពិសេសមុន បានគូសបញ្ជាក់នៅក្នុងរបាយការណ៍ដែលបានចេញផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច ដោយផ្អែកលើទស្សនៈវិស័យខាងសិទ្ធិមនុស្ស[៤] អំពីសេចក្តីត្រូវការជាបន្ទាន់ចំពោះការផ្សព្វផ្សាយជាសាធារណៈ និងយន្តការនៃការទទួលខុសត្រូវ ។ ការធ្វើបែបនេះ អាចជួយឱ្យសាធារណៈជនបានយល់ដឹងយ៉ាងពេញលេញអំពីប្រព័ន្ធទូទៅនៃសម្បទាន និងផលប៉ះពាល់របស់វាលើផលប្រយោជន៍ប្រជាពលរដ្ឋកម្ពុជាក្នុងពេលបច្ចុប្បន្ន និងអនាគត ។ ប្រទេសអ្នកផ្តល់ជំនួយបានស្នើហើយស្នើទៀតដល់រដ្ឋាភិបាល ហើយរដ្ឋាភិបាលក៏បានសន្យាហើយសន្យាទៀតថានឹងបង្កើតឱ្យមានយន្តការនេះ ។ សន្ទស្សន៍ត្រួតពិនិត្យរួម ដែលបានអនុម័តយល់ព្រមនៅក្នុងសម័យប្រជុំក្រុមពិគ្រោះយោបល់សំរាប់ប្រទេសកម្ពុជាលើកទីប្រាំពីរក្នុងខែធ្នូ ឆ្នាំ២០០៤ រួមមានការផ្សព្វផ្សាយជាបន្ទាន់ព័ត៌មានអំពីសម្បទានរ៉ែ និងតំបន់អភិវឌ្ឍន៍យោធា ។ ការស្នើសុំការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងនេះ ដើម្បីតម្លាភាព បានធ្វើឡើងទៀតនៅឯសម័យប្រជុំលើកទីប្រាំបី នៃក្រុមពិគ្រោះយោបល់ ខែមីនា ឆ្នាំ២០០៦ ។

៧៩. ការផ្សព្វផ្សាយព័ត៌មានស្តីពីការគ្រប់គ្រងដី និងធនធានធម្មជាតិ រឹតតែមានសារៈសំខាន់ថែមទៀត ជាពិសេសចំពោះរបកគំហើញនៃរ៉ែប្រេងនៅឈូងសមុទ្រថៃ ។ ក្រុមហ៊ុនប្រេងឥន្ធនៈបរទេសជាច្រើន ត្រូវបានគេរាយការណ៍ថាបានចុះកិច្ចសន្យាដើម្បីធ្វើអាជីវកម្ម ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចសន្យាទាំងនេះ មិនដាក់ឱ្យសាធារណៈជនឱ្យរកមើលបានទេ ។ មានក្រុមហ៊ុនរ៉ែបរទេសពីរ ត្រូវបានផ្តល់អាជ្ញាប័ណ្ណស្រាវជ្រាវរករ៉ែបុកស៊ីតលើផ្ទៃដី ១០០.០០០ ហិកតា នៅក្នុងខេត្តនានានៅភាគឦសាន្ត ដែលនៅទីនោះប្រជាពលរដ្ឋភាគច្រើនជាជនជាតិដើមភាគតិច ។ ទាំងទំហំទីតាំងភូមិសាស្ត្រនៃអាជ្ញាប័ណ្ណ ទាំងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ មិនត្រូវបានផ្សព្វផ្សាយឱ្យដឹងជាសាធារណៈឡើយ ទោះបីជាមានកង្វល់អំពីផលប៉ះពាល់ សំរាប់ថ្ងៃអនាគតលើជនជាតិដើមភាគតិច និងបរិស្ថានក៏ដោយ ។

---

[៤] របាយការណ៍មានចំណងជើងថា " សម្បទានដីគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស " ដែលអាចរកឃើញក្នុងវិបសាយ http://cambodia.ohchr.org/report_subject.aspx

## គ. ជនជាតិដើមភាគតិច និងការប្រើប្រាស់ដីធ្លី

៨០. ដូចគ្នានឹងប្រជាពលរដ្ឋដទៃទៀតនៅជនបទ សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ជួបប្រទះបញ្ហាស្រដៀងគ្នា ទាក់ទងនឹងការបាត់បង់ដីធ្លី ហើយសំរាប់ជនជាតិដើមភាគតិចមានផលប៉ះពាល់ជាបន្ថែមទៀត លើទំនាក់ទំនងពិសេស រវាងវប្បធម៌ និងជំនឿ ជាមួយដីធ្លី និងការពឹងអាស្រ័យលើដីព្រៃឈើដែលជាប្រភពនៃការចិញ្ចឹមជីវិត និង អត្តសញ្ញាណ ។

៨១. មានកង្វល់ជាទូទៅអំពីអនាគតរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដោយសារពួកគេបន្តបាត់បង់ដីព្រៃឈើយ៉ាងឆាប់រហ័យ ទៅក្នុងដៃបុគ្គលឯកជន និងក្រុមហ៊ុន តាមរយៈការលក់ដីដោយការបង្ខិតបង្ខំ និងដោយខុសច្បាប់ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច ។ ការកើនឡើងគួរឱ្យភ្ញាក់ផ្អើលនៃអត្រាផ្ទេរកម្មសិទ្ធិដីធ្លី មានផលវិបាកយ៉ាងធ្ងន់ធ្ងរដល់សង្គម វប្បធម៌ និងបរិស្ថាន ដែលទាមទារឱ្យចាត់វិធានការជាបន្ទាន់ ដើម្បីកុំឱ្យហួសពេល ។

៨២. របាយការណ៍មួយដែលបានចេញផ្សាយក្នុងខែឧសភា ឆ្នាំ២០០៦ ដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ជាអង្គការនៃមាជិកភាពដែលធ្វើការផ្លាស់ប្តូរព័ត៌មាន ជជែកដេញដោល និងតស៊ូមតិលើបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា បានធ្វើការប៉ាន់ស្មានថាគិតតែខេត្តរតនគិរីមួយប៉ុណ្ណោះ នៅចន្លោះពីចុងឆ្នាំ ២០០៤ ដល់ដើមឆ្នាំ២០០៦ ការផ្ទេរកម្មសិទ្ធិដីធ្លីបានកើនឡើងយ៉ាងខ្លាំងគឺ ៣០ភាគរយនៃចំនួនឃុំសង្កាត់ទាំងអស់ ហើយនៅសល់ ៧០ភាគរយទៀត ការផ្ទេរកម្មសិទ្ធិកំពុងតែបន្តឥតឈប់ឈរ ។ នៅក្នុងខេត្តមួយចំនួនដូចជាខេត្តរតនគិរី មណ្ឌលគិរី និងស្ទឹងត្រែង ដែលមានចំនួនជនជាតិដើមភាគតិចច្រើនរស់នៅ ការដណ្តើមយកដីធ្លី និងសម្បទានដីគោលដៅសេដ្ឋកិច្ច បាននាំឱ្យមានការកាប់បំផ្លាញព្រៃឈើ និងការបាត់បង់របរចិញ្ចឹមជីវិត និងការប្រើប្រាស់ដីធ្លី ។

៨៣. ច្បាប់ភូមិបាលទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច នូវកម្មសិទ្ធិសមូហភាពលើដីធ្លីរបស់ខ្លួនដែលរួមមានទាំងដីសំរាប់សង់លំនៅដ្ឋាន និងដីកសិកម្មជាប្រពៃណីផងដែរ ។ ប័ណ្ណកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច អាចត្រូវបានផ្តល់លើដីឯកជន ឬដីសាធារណៈរបស់រដ្ឋ ។ ទន្ទឹមនឹងមានការទទួលស្គាល់ពីសារសំខាន់នៃសិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច កិច្ចដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច បានអូសបន្លាយពេលវែង និងគ្មានលក្ខណៈប្រាកដប្រជា ។ គំរោងសាកល្បងមួយចំនួនកំពុងដំណើរការចុះបញ្ជីដីជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគិរី និងរតនគិរី ប៉ុន្តែកិច្ចដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិសមូហភាព និងក្របខ័ណ្ឌគោលនយោបាយ ទូទៅមិនមានភាពច្បាស់លាស់ មិនមានក្រសួងណាមួយត្រូវបានចាត់តាំងឱ្យដឹកនាំធ្វើកិច្ចការនេះទេ ។

៨៤.	នៅក្នុងសម័យប្រជុំក្រុមពិគ្រោះយោបល់រវាងប្រទេសអ្នកផ្ដល់ជំនួយ និងរដ្ឋាភិបាល កាលពីខែមីនា ឆ្នាំ ២០០៦ មានការឯកភាពគ្នាថា ក្របខ័ណ្ឌច្បាប់ និងយុទ្ធសាស្ត្រស្ដីពីជនជាតិដើមភាគតិច នឹងត្រូវធ្វើឱ្យចប់សព្វគ្រប់ នៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០៦។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមិនទាន់មានគោលនយោបាយ ឬយុទ្ធសាស្ត្រស្ដីពីរបៀបការពារ និងអនុវត្តសិទ្ធិជនជាតិដើមភាគតិច រួមទាំងសិទ្ធិលើដីធ្លីរបស់ពួកគេទេ។

៨៥.	សំនួរដែលចោទសួរជាទូទៅនោះគឺ : តើនៅសល់ដីប៉ុន្មានសំរាប់ផ្ដល់ប័ណ្ណកម្មសិទ្ធិសមូហភាព នៅពេលដែលកិច្ចដំណើរការរដ្ឋបាលពាក់ព័ន្ធការចុះបញ្ជីប័ណ្ណកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចត្រូវបានបញ្ជាក់ច្បាស់? ។ កិច្ចដំណើរការ និងផលប៉ះពាល់នៃការផ្ទេរកម្មសិទ្ធិដីជនជាតិដើមភាគតិចត្រូវបានអង្គការក្រៅរដ្ឋាភិបាលចងក្រងជាឯកសារ ហើយបានគូសបញ្ជាក់ពីសេចក្ដីត្រូវការជាបន្ទាន់ នូវវិធានការបណ្ដោះអាសន្ន ដើម្បីការពារដីស្របច្បាប់សំរាប់កម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច។

## ឃ. ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ទាក់ទងនឹងដីធ្លី និងធនធានធម្មជាតិ

៨៦.	លោកតំណាងពិសេសមានកង្វល់អំពីបរិយាកាសលំបាកកាន់តែខ្លាំងឡើងៗ ដែលប្រឈមមុខដោយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនសហគមន៍នានា ដែលគាំទ្រដល់សិទ្ធិស្មើគ្នាលើដីធ្លី និងធនធានធម្មជាតិ។ លោកបានទទួលរបាយការណ៍ជាហូរហែរ អំពីការរិតត្បិតលើសកម្មភាព សិទ្ធិជួបប្រជុំ និងសេរីភាពក្នុងការធ្វើដំណើររបស់ពួកគេ និងសកម្មភាពនៃការបំភិតបំភ័យពីសំណាក់អាជ្ញាធរ និងសន្តិសុខក្រុមហ៊ុន។

៨៧.	នៅពេលថ្មីៗនេះ សកម្មជនសិទ្ធិមនុស្សមួយរូប នៅខេត្តរតនគីរីបានទទួលការគំរាមកំហែងដល់អាយុជីវិតទាក់ទងនឹងការងាររបស់គាត់ក្នុងករណីជំលោះដីធ្លី ដែលរយៈពេលកន្លងមក គាត់ក៏បានរងនូវការគំរាមកំហែង និងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ដោយសារតែសកម្មភាពការងារពាក់ព័ន្ធនឹងដីធ្លីរបស់គាត់។ នៅខេត្តមណ្ឌលគីរី អាជ្ញាធរបន្តគ្រប់គ្រងលើការងាររបស់អង្គការក្រៅរដ្ឋាភិបាល និងសកម្មជនសហគមន៍នានា តាមរយៈការបង្គាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាលនានាផ្ដល់របាយការណ៍ឱ្យខ្លួនយ៉ាងទៀងទាត់អំពីសកម្មភាព និងគំរោងផែនការរបស់ខ្លួន ហើយតម្រូវឱ្យសកម្មជនសហគមន៍ផ្សេងៗសុំការអនុញ្ញាតមុននឹងចូលរួមប្រជុំនៅក្រៅខេត្ត។ ក្នុងករណីជាច្រើន អាជ្ញាធរបានចោទប្រកាន់ អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនតាមភូមិថា បានញុះញង់ឱ្យមានបញ្ហានៅក្នុងសហគមន៍ទាំងឡាយ ដែលរងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច និងជំលោះដីធ្លី ដោយប្រើពាក្យនេះធ្វើជាលេសដើម្បីរិតត្បិតសកម្មភាពរបស់ពួកគេ។ នៅខេត្តកោះកុង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល មិនត្រូវបានអនុញ្ញាតឱ្យចូល

ទៅកាន់តំបន់ដែលមានផលប៉ះពាល់ដោយសម្បទានសេដ្ឋកិច្ចទេ ហើយពួកគេត្រូវបានតំរូវឱ្យសុំការអនុញ្ញាតពីអជ្ញាធរ បើសិនជាពួកគេចង់ជួបប្រជុំជាមួយអ្នកភូមិក្នុងតំបន់នោះ ។ នៅខេត្តពោធិសាត់ អាជ្ញាធរមូលដ្ឋានបានប្រាប់សមាជិកសហគមន៏ដែលស្ថិតនៅជិតសម្បទានដីសេដ្ឋកិច្ចមួយកន្លែងទៀត មិនឱ្យចូលរួមក្នុងសកម្មភាពទាំងឡាយ ដែលបានរៀបចំឡើងដោយសកម្មជនសហគមន៏ទេ ដោយចោទប្រកាន់ថា ពួកគេទទួលការគាំទ្រពីគណៈបក្សសមរង្សី ។

៨៨. លោកតំណាងពិសេសមានកង្វល់ជាពិសេសអំពីការកើនកាន់តែច្រើនឡើង១ នៃចំនួនសកម្មជនសហគមន៏នានាដែលប្រឈមមុខនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ទាក់ទងនឹងជំលោះដីធ្លី និងសកម្មភាពការងាររបស់ពួកគេពាក់ព័ន្ធនឹងដីធ្លី ។ លោកបានទទួលរបាយការណ៏ជាច្រើនអំពីសកម្មជនសហគមន៏រងការចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិឯកជន ឬបទល្មើសព្រហ្មទណ្ឌដទៃទៀត ដែលមានចែងក្នុងច្បាប់ភូមិបាល ទាក់ទងនឹងជំលោះដីធ្លីមិនទាន់ចុះបញ្ជី ។ ប្រព័ន្ធច្បាប់ហាក់កំពុងត្រូវបានគេប្រើដើម្បីការពារបុគ្គលដែលមានអំណាច និងឥទ្ធិពល ជាជាងការផ្តល់ការការពារ និងយុត្តិធមិដល់សហគមន៏ និងជនក្រីក្រ ។

## VII. **សហគមន៍អន្តរជាតិ**

៨៩. នៅក្នុងកិច្ចព្រមព្រៀងសន្តិភាព បណ្តាប្រទេសហត្ថលេខីមានភារកិច្ចលើកស្ទួយ និងជំរុញឱ្យមានការគោរព និងការប្រតិបត្តិសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តនៅកម្ពុជា ដូចមានចែងក្នុងលិខិតុបករណ៏អន្តរជាតិ ជាពិសេស ដើម្បីរារាំងការវិលត្រឡប់មកវិញនូវការរំលោភសិទ្ធិមនុស្ស ។ កិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាពទឹកដី និងភាពមិនអាចរំលោភបាន អព្យាក្រឹតភាព និងឯកភាពជាតិនៃកម្ពុជា មានរួមបណ្ចូលបទបញ្ញត្តិពាក់ព័ន្ធនឹងករណីនៃការរំលោភកិច្ចព្រមព្រៀងនេះផង រួមទាំងបទបញ្ញត្តិស្តីពីសិទ្ធិមនុស្ស ។ ទាំងនេះមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដោយភាគីនៃកិច្ចព្រមព្រៀងនេះ ដើម្បីដោះស្រាយការរំលោភដោយមធ្យោបាយសន្តិវិធី បញ្ជូនទៅក្រុមប្រឹក្សាសន្តិសុខ ឬតាមរយៈមធ្យោបាយដោះស្រាយជំលោះដោយសន្តិវិធី អនុលោមតាមមាត្រា៣៣ នៃធម្មនុញ្ញសហប្រជាជាតិ ។

៩០. លោកតំណាងពិសេសបានគូសបញ្ជាក់ពីការទទួលខុសត្រូវតាមផ្លូវច្បាប់ និងសីលធមិ របស់សហគមន៏អន្តរជាតិនិងសមាជិករបស់ខ្លួន គាំទ្រកម្ពុជា ក្នុងបេសកកម្មរបស់ខ្លួន ដើម្បីពង្រឹងសិទ្ធិមនុស្ស និងស្ថាប័នដែលមានការទទួលខុសត្រូវ និងប្រជាធិបតេយ្យទោះក្នុងនាមជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀង ជារដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ឬជារដ្ឋភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សក៏ដោយ ។ នេះគឺជាសនិទានភាពបឋមចំពោះកិច្ចការរបស់ពួកគេនៅកម្ពុជា នាដើមទសវត្សរ៏ឆ្នាំ១៩៩០ ។

៩១. រដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការកំណែទម្រង់ជាបន្តបន្ទាប់ ដែលនិយាយអំពីអភិបាលកិច្ច ទិសដៅអភិវឌ្ឍន៍សហសវត្សរ៍ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ការកាត់បន្ថយភាពក្រីក្រ នីតិរដ្ឋកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ។ ទោះជាដូច្នេះក្តី រដ្ឋាភិបាលមិនអើពើទាល់តែសោះចំពោះបញ្ហាស្នូល ដែលបានលើកឡើងក្នុងរបាយការណ៍នេះ និងក្នុងរបាយការណ៍មុនៗ របស់លោកតំណាងពិសេសនានា ។

៩២. មានផែនការកំណែទម្រង់ជាច្រើននៅមិនទាន់បានអនុវត្តនៅឡើយ ហើយភាពជឿនលឿនមានសន្ទុះយឺតជាងការរំពឹងទុក ដែលតែងតែទំលាក់កំហុសដល់សមត្ថភាពរបស់ស្ថាប័ននៅតែទន់ខ្សោយ កង្វះការសំរបសំរួលក្នុងចំណោមប្រទេសអ្នកផ្តល់ជំនួយ តំរូវការប្រណាំងប្រជែងគ្នាច្រើនពីស្ថានប័នរដ្ឋាភិបាលនានាដែលមិនរឹងមាំ និងកង្វះខាតអ្នកដែលមានសមត្ថភាព កេរ្តិ៍ដំណែលពីរបបខ្មែរក្រហម ។ ទន្ទឹមនឹងបញ្ហាទាំងនេះអាចមានសុពលភាពខ្លះនោះ លោកតំណាងពិសេសបានសន្និដ្ឋានថា ការពិតបុគ្គលទាំងឡាយដែលកាន់អំណាចនយោបាយ និងសេដ្ឋកិច្ច មានការរារែកគាំទ្រឱ្យមានកំណែទម្រង់ពិតប្រាកដ ព្រោះតែពួកគេពឹងផ្អែកលើការកាន់អំណាច ទទួលបានប្រយោជន៍ពីការកាន់អំណាចរបស់ខ្លួន លើស្ថាប័នរដ្ឋនានា ដើម្បីរក្សាអំណាចតទៅទៀត ។

៩៣. ប្រាកដណាស់ថា កិច្ចសហប្រតិបត្តិការបច្ចេកទេស ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពតែប៉ុណ្ណឹងនឹងមិនសំរេចបានដោយគ្មានការដោះស្រាយបញ្ហាទាំងឡាយដែលបានគូសបញ្ជាក់ និងគ្មានការទាមទារយ៉ាងមុតមាំមួយចំពោះការទទួលខុសត្រូវទនោះ ។ ការប្រើអំពើរំលោភសិទ្ធិមនុស្សជាប្រព័ន្ធ បានក្លាយជាជំរើសដ៏សមហេតុផលមួយសំរាប់អ្នកទាំងឡាយដែលកាន់អំណាចនៅកម្ពុជា និងអ្នកទាំងឡាយដែលប្រកែកមិនទទួលយក ការទទួលខុសត្រូវចំពោះមុខច្បាប់ និងចំពោះមុខប្រជាជនកម្ពុជា ។ ជំរើសផ្សេងៗទៀតក៏អាចធ្វើបានដែរ ប្រសិនបើតំលៃនៃការគាប់សង្កត់ ត្រូវបានមើលឃើញថាមានទំហំធំធេងជាងផលប្រយោជន៍ចំពោះមុខរបស់ខ្លួន ។

៩៤. ដូចភស្តុតាងពីប្រវត្តិសាស្ត្រថ្មីៗនេះរបស់កម្ពុជា និងនៅទីកន្លែងផ្សេងទៀត បង្ហាញពីការគាបសង្កត់ ការបំភិតបំភ័យ និងការជំរិតយកប្រាក់ អាចបង្កើតជាបុរេលក្ខខណ្ឌ សំរាប់អំពើហឹង្សាតបតវិញយ៉ាងធ្ងន់ធ្ងរ ។ នាយករដ្ឋមន្ត្រីខ្លួនលោកផ្ទាល់បានទទួលស្គាល់ពីបញ្ហានេះ ឧទាហរណ៍ ក្នុងសេចក្តីថ្លែងការណ៍របស់លោកអំពីការចាប់យកដីធ្លី ។

៩៥. របាយការណ៍និងអនុសាសន៍ទាំងឡាយរបស់តំណាងពិសេសនានា សេចក្តីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្ស និងមហាសន្និបាតអង្គការសហប្រជាជាតិ និងសេចក្តីសង្កេតចុងក្រោយ និងអនុសាសន៍របស់ស្ថាប័ននានានៃសន្ធិសញ្ញាសិទ្ធិមនុស្ស គួរតែដាក់បញ្ចូលគ្នាទាំងអស់ជាផ្នែកទាំងស្រុងមួយនៃការពិភាក្សារវាងរដ្ឋាភិបាល និងទីភ្នាក់ងារនានានៃប្រទេសផ្តល់ជំនួយ ។ ហើយប្រទេសជិតខាងកម្ពុជា និងរដ្ឋាភិបាលនានាដែលមានឥទ្ធិពលនៅតំបន់អាស៊ី

ជាពិសេស ប្រទេសទាំងឡាយដែលផ្តល់ជំនួយអភិវឌ្ឍន៍ច្រើន និងកម្ចីដល់រដ្ឋាភិបាលកម្ពុជា គួរតែសកម្មខ្លាំងក្លាជាងនេះថែមទៀត ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន ចំពោះប្រទេស និងប្រជាជនកម្ពុជា ។

## VIII. សេចក្តីសន្និដ្ឋាន

៩៦. ក្រោយពីសង្គ្រាមស៊ីវិលបានបញ្ចប់ សន្តិសុខទូទៅនៅកម្ពុជាមានភាពល្អប្រសើរ ។ ប៉ុន្តែការនៅខ្វះស្ថាប័នរដ្ឋាភិបាលដែលមានប្រសិទ្ធភាព ច្បាប់ជាមូលដ្ឋាន និងប្រព័ន្ធតុលាការមួយដែលមិនលំអៀង អមទៅដោយបញ្ហានិទណ្ឌភាពដែលកំពុងតែមានបន្ត និងការគំរាមកំហែងដល់អ្នករិះគន់ចំពោះស្ថានភាពបច្ចុប្បន្ន ការគ្មានដីធ្លីដែលចេះតែកើនឡើង និងចំនួនជនបម្លាស់ទីកន្លែងកាន់តែកើនច្រើនឡើង ទាំងអស់នេះធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាមិនមានសន្តិសុខងាយរងគ្រោះពីការបដិសេធ និងការរំលោភជាប្រព័ន្ធលើសិទ្ធិរបស់ពួកគេ ហើយប្រឈមមុខនឹងវិធីសាស្រ្តល្បិតល្បួនក្នុងការរក្សាសណ្តាប់ធ្នាប់នយោបាយ និងសេដ្ឋកិច្ចដែលមានស្រាប់ ។

៩៧. បញ្ហាមួយចំនួនដែលកម្ពុជាជួបប្រទះសព្វថ្ងៃនេះគឺខុសប្លែកពីគេ ។ អំពើពុករលួយដែលចាក់ឫសជ្រៅនៅថ្នាក់លើបំផុត ប្រព័ន្ធមួយដែលផ្អែកលើបរិបាលកិច្ច ការលួចប្លន់យកធនធានធម្មជាតិ យុទ្ធសាស្រ្តបំបែក និងគ្រប់គ្រងការប្រើប្រាស់រចនាសម្ព័ន្ធរដ្ឋដើម្បីបំផ្លាញគណបក្សប្រឆាំង និងការធ្វើមានបាននៃមនុស្សមួយក្រុមតូចដោយមិនគិតគូរដល់មនុស្សភាគច្រើនទៀត ទាំងអស់នេះគឺជាបាតុភូតស្រដៀងគ្នាដែលត្រូវបានសិក្សានៅក្នុងប្រទេសជាច្រើន រួមមានអាស៊ីបូព៌ា និងប្រទេសដទៃទៀតក្រោយពីសង្គ្រាម ។ ទោះជាដូច្នេះក្តី ប្រទេសកម្ពុជានៅតែខុសប្លែកពីគេត្រង់ថាសហគមន៍អន្តរជាតិបានដើរតួនាទីដ៏សំខាន់មួយ ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពក្នុងការកសាងប្រទេស និងស្ថាប័ននៃប្រទេសនេះឡើងវិញ ក្នុងគោលបំណងបង្កើតរបបមួយ ដែលផ្អែកលើការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ ។

៩៨. លោកតំណាងពិសេសសំដែងនូវការសោកស្តាយថា ជំនួសឱ្យការឆ្លើយតបទៅនឹងកង្វល់របស់លោកតំណាងពិសេសនានា និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ការឆ្លើយតបជារឿយៗរបស់រដ្ឋាភិបាល គឺជាការគេចវេះឬការចោទប្រកាន់ ការទម្លាក់កំហុសឱ្យអ្នកដទៃ និងការបំភិតបំភ័យ ។

៩៩. ការការពារ និងការទទួលបានសិទ្ធិមនុស្សមានសារៈសំខាន់ ដើម្បីធានារក្សាកេរ្តិ៍តំណែលសន្តិភាព ជាមួយនឹងយុត្តិធម៌សំរាប់កម្ពុជា រយៈពេល១៥ឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាព និង២៧ឆ្នាំបន្ទាប់ពីការបញ្ចប់ទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

១០០.   ការសន្យាដ៏សំខាន់ ត្រូវបានធ្វើឡើងចំពោះប្រជាជនកម្ពុជា ដែលមិនអាចត្រូវបានបោះបង់ចោលឡើយ ។ នេះគឺជាភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដើម្បីដាក់ឱ្យដំណើការនូវគោលនយោបាយ និងច្បាប់ផ្សេងៗ ដើម្បីបំពេញការសន្យាទាំងនេះ ហើយសហគមន៏អន្តរជាតិ មានភារកិច្ចជួយប្រទេសកម្ពុជាក្នុងការបំពេញការសន្យាទាំងនេះ ។ រិតតែសំខាន់ជាងនេះទៀតនោះ គឺរដ្ឋាភិបាល គណបក្សកាន់អំណាច គណបក្សនយោបាយដទៃទៀត និង វរជនពាណិជ្ជកម្មដ៏មានអំណាចទាំងអស់នៃកម្ពុជា គួរប្រព្រឹត្តឱ្យបានល្អ ដើម្បីបង្ហាញពីបែបផែននៃសង្គម ដែលខ្លួនចង់បានសំរាប់ប្រទេសកម្ពុជា ។

១០១.   នៅក្នុងសារលិខិតរបស់លោកថ្លែងទៅកាន់កុមារ និងយុវជនកម្ពុជា ក្នុងទិវាសិទ្ធិមនុស្សឆ្នាំ២០០៥ លោកតំណាងពិសេស បានសំដែងនូវកង្វល់ថា ឥរិយាបទចំពោះសិទ្ធិមនុស្ស បានក្លាយជាមូលហេតុនៃការមិនចុះសំរុងគ្នានៅកម្ពុជា ដែលមនុស្សមួយចំនួនចាត់ទុកអ្នកតស៊ូមតិខាងសិទ្ធិមនុស្ស ថាជាឧបសគ្គដល់ការអភិវឌ្ឍន៏ ហើយដែលតាមការអះអាងបែបនេះ អត្ថន័យពិតប្រាកដនៃសិទ្ធិមនុស្សកំពុងតែត្រូវបាត់បង់ ។

១០២. លោកបានគូសបញ្ជាក់ថា គោលការណ៏ជាមូលដ្ឋាននៃសិទ្ធិមនុស្ស គឺថាមនុស្សទាំងអស់មានសមភាពក្នុងសិទ្ធិនិងសេចក្តីថ្លៃថ្នូរ ដោយមិនគិតថាបុគ្គលនោះមានឬក្រ ក្មេងឬចាស់ ទន់ខ្សោយឬមានអំណាចឡើយ ។ ទន្ទឹមនឹងសិទ្ធិនេះ អាចធ្វើឱ្យជ្រួលច្របល់ដល់របៀបរៀបរយនៃបញ្ហាបច្ចុប្បន្ននេះ វាបង្កើតលទ្ធភាពនៃទំនាក់ទំនងគ្នា ផ្អែកលើការគោរពគ្នានិងភាពស្មើគ្នា ។

១០៣. សាមគ្គីភាព ជាគោលការណ៏សំខាន់មួយទៀតនៃសិទ្ធិមនុស្ស ទទួលស្គាល់ថា យើងទាំងអស់គ្នាជាមនុស្ស ដែលយើងរំលែកសេចក្តីត្រូវការ និងសេចក្តីប្រាថ្នាដូចគ្នា ដែលយើងគួរប្រព្រឹត្តចំពោះមនុស្សទាំងអស់នៅជុំវិញខ្លួនយើងដោយការអត់ឱនឱ្យគ្នា ការគោរព និងការយោគយល់គ្នា ។ តាមរយៈសិទ្ធិសំដែងមតិ និងសិទ្ធិបង្កើតសមាគម យើងជាសហគមន៏ អាចផ្លាស់ប្តូរយោបល់គ្នាដោយសន្តិវិធី និងដោយសហការគ្នា ។

១០៤. សិទ្ធិមនុស្សសំដៅផងដែរដល់ការទទួលខុសត្រូវរបស់យើងចំពោះអ្នកជិតខាងយើង និងសង្គមរបស់យើង ហើយសិទ្ធិមនុស្សនិយាយអំពីការការពាររបស់យើងទល់នឹងការគ្រប់គ្រងដែលអយុត្តិធមិ ឬដែលសង្កត់សង្កិន បង្កើតវិធានស្តីពីទំនាក់ទំនងរវាងប្រជាជននិងរដ្ឋ ។ សិទ្ធិមនុស្ស ផ្តល់លទ្ធភាពឱ្យប្រជាជនជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន និងកំណត់ពីគោលនយោបាយរបស់រដ្ឋ ។ សិទ្ធិមនុស្សនិយាយអំពីការពិភាក្សា និងការចូលរួម ។ សិទ្ធិមនុស្ស ធានាឱ្យមានការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងសេចក្តីសុចរឹតនៃអ្នកដឹកនាំរបស់ខ្លួន ។ គំនិតនៃសេចក្តីថ្លៃថ្នូរ ដែលសំខាន់បំផុតចំពោះសិទ្ធិមានន័យថា សង្គមត្រូវខិតខំធានាថា ជនគ្រប់រូបមានសន្តិសុខ ហើយធានាថា សេចក្តីត្រូវការជាមូលដ្ឋានរបស់គេដូចជា

ស្បៀងអាហារ ជំរក សំលៀកបំពាក់ និងទឹកស្អាតជាអប្បបរមា ត្រូវបានបំពេញ។ ប្រសិនជាគ្មានលក្ខខណ្ឌទាំងនេះទេ មនុស្សមិនអាចចូលរួមដោយឈរលើគោលការណ៍ស្មើភាពគ្នាទេ ហើយមិនអាចមានយុត្តិធម៌ឡើយ។

១០៥. លោកតំណាងពិសេសសង្ឃឹមថានឹងពិភាក្សារបាយការណ៍នេះ និងអនុសាសន៍របស់លោកនៅក្នុងបេសកកម្មលើក្រោយមកកាន់ប្រទេសកម្ពុជា នៅដើមឆ្នាំ២០០៧ នៅមុនពេលធ្វើបទបង្ហាញរបាយការណ៍ និងអនុសាសន៍នេះជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងសម័យប្រជុំលើកទីបួន។ លោកបានបញ្ចប់របាយការណ៍នេះនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៦។

## IX. **អនុសាសន៍**

១០៦. ដោយសារអំពើរំលោភដោយចេតនា និងជាប្រព័ន្ធលើសិទ្ធិមនុស្ស បានក្លាយជាចំណុចស្នូលរបស់រដ្ឋាភិបាលក្នុងការកាន់អំណាច សហគមន៍អន្តរជាតិដែលជាប់កាតព្វកិច្ចដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស គួរធ្វើគ្រប់បែបយ៉ាងដែលអាចធ្វើបាន ដើម្បីបញ្ចុះបញ្ចូល និងគាបសង្កត់រដ្ឋាភិបាលឱ្យគោរពការសន្យារបស់ខ្លួនចំពោះសិទ្ធិមនុស្សតាមកិច្ចព្រមព្រៀង សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជា។ ចំណែករដ្ឋាភិបាល ត្រូវប្រកាសឱ្យបានច្បាស់ដល់សហគមន៍អន្តរជាតិ និងប្រជាជនកម្ពុជា ពីកាតព្វកិច្ចរបស់ខ្លួន ទាំងផ្នែកច្បាប់និងផ្នែកសីលធម៌ ថាឈប់រំលោភសិទ្ធិ ហើយគោរពឯករាជ្យភាពរបស់តុលាការ និងអាជ្ញាធរអយ្យាការ។

១០៧. លោកតំណាងពិសេសគួសបញ្ជាក់ជាថ្មី ពីការអញ្ជើញរបស់លោកដល់រដ្ឋាភិបាល ឱ្យទៅបំភ្លឺក្រុមប្រឹក្សាសិទ្ធិមនុស្ស អំពីការចាត់វិធានការជាក់ស្តែងរបស់រដ្ឋាភិបាល និងពីបំណងឆ្លើយតបចំពោះអនុសាសន៍ដែលលោក និងតំណាងពិសេសមុនៗបានផ្តល់ និងចំពោះអនុសាសន៍របស់ស្ថាប័ននានានៃសន្ធិសញ្ញា និងចំពោះសហគមន៍អន្តរជាតិ តាមរយៈសេចក្តីសំរេចចិត្តនៃមហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសិទ្ធិមនុស្ស។

១០៨. អនុសាសន៍ខាងក្រោមនេះ រួមទាំងអនុសាសន៍កន្លងមក ដែលមិនបានលើកឡើងក្នុងតួសេចក្តីនៃរបាយការណ៍នេះ។ អនុសាសន៍ទាំងនេះអាចចាត់ទុកថាជាការបង្កើតធាតុផ្សំជាមូលេគុលនៃផែនការសកម្មភាពសំរាប់សិទ្ធិមនុស្សនៅកម្ពុជា៖

**នីតិរដ្ឋ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត**

- អនុម័តវិធានការជាបញ្ហាអាទិភាព ដើម្បីធានាឯករាជ្យភាព អនាគតិ និងប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងប្រព័ន្ធយុត្តិធម៌ទាំងមូល ហើយអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិប្រើប្រាស់ស្ថាប័នទាំងនេះឱ្យមានប្រសិទ្ធភាព ដើម្បីពង្រឹងសិទ្ធិរបស់ខ្លួន ។

- បញ្ចប់ អនុម័ត និងអនុវត្តច្បាប់ និងក្រមទាំងឡាយដែលជាផ្នែកដ៏សំខាន់នៃនីតិរដ្ឋស្របតាមរដ្ឋធម្មនុញ្ញនិងលិខិតុបករណ៍អន្តរជាតិ ។

- លើកកំពស់សិទ្ធិប្រជាពលរដ្ឋកម្ពុជាទាំងអស់ ឱ្យធ្វើសកម្មភាពលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដោយធានាឱ្យមានការគោរពយ៉ាងពេញលេញចំពោះសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដែលត្រូវបានទទួលស្គាល់ជាសកល ។

- ការពារយ៉ាងពេញទំហឹងដល់សេរីភាពនៃការសំដែងមតិ ការប្រមូលផ្តុំដោយសន្តិវិធីនិងសិទ្ធិបង្កើតសមាគមស្របតាមរដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍អន្តរជាតិ ។ ធានាថាច្បាប់ថ្មីណាក៏ដោយត្រូវស្របតាមលិខិតុបករណ៍ទាំងនេះ ។ លុបចោលបទបញ្ញត្តិមួយចំនួននៅក្នុងច្បាប់ ស្តីពីការបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ ។ ធានាសិទ្ធិទទួលបានព័ត៌មាន ដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ ។

- ធានាថាមន្ត្រីអនុវត្តច្បាប់បំបែកបាតុកម្ម និងការប្រមូលផ្តុំ បានតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ ។ ប្រើប្រាស់កំលាំងតែក្នុងមធ្យោបាយចុងក្រោយបំផុតប៉ុណ្ណោះ ហើយសមាមាត្រនឹងការគំរាមកំហែងដែលបានបង្កឡើង ដោយមានការខូចខាត ឬរបួសតិចតួចបំផុតដល់មនុស្ស និងទ្រព្យសម្បត្តិ ។

- បញ្ឈប់ការជម្លៀសចេញដោយបង្ខំ ។

- ធ្វើការស៊ើបអង្កេតដោយមិនលំអៀង និងដែលអាចជឿទុកចិត្តបានចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទាំងក្នុងអតីតកាល និងបច្ចុប្បន្នកាល ។ នាំខ្លួនជនទាំងឡាយដែលទទួលខុសត្រូវទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ។ ឃាតកម្មលើរូបលោកជា វិជ្ជា ប្រធានសហជីពជាឧទាហរណ៍ស្រាប់ ។

- បង្កើតគណៈកម្មការឯករាជ្យមួយ ស៊ើបអង្កេតបណ្តឹងទាំងឡាយដែលពាក់ព័ន្ធនឹងអំពើប្រព្រឹត្តរបស់យោធាឬនគរបាល ។

- បញ្ឈប់ការយកចំលើយសារភាពដោយបង្ខំ មកធ្វើជាភស្តុតាងនៅសវនាការ ។ បង្កើតប្រព័ន្ធនៃការត្រួតពិនិត្យជាទៀងទាត់មួយ សំរាប់អង្គការក្រៅរដ្ឋាភិបាលចូលដល់បន្ទប់ និងមន្ទីរឃុំឃាំងនានារបស់នគរបាល ដើម្បីបង្ការមិនឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។ ផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ហើយអនុវត្តន៏បទបញ្ញត្តិនៃពិធីសារនេះ ។

- ពិនិត្យឡើងវិញនូវគោលនយោបាយផ្តន្ទាទោស ។ បញ្ចូលជំរើសមិនឃុំខ្លួនជំនួសឱ្យការដាក់ពន្ធនាគារ ហើយជំរើសនេះត្រូវអនុវត្តដំបូងគេបង្អស់សំរាប់អ្នកទោសជាអនីតិជន ។

- ធានាថា មេធាវី សមាជិកគ្រួសារ និងអង្គការសិទ្ធិមនុស្សទាំងអស់ មានសិទ្ធិចូលសួរសុខទុក្ខអ្នកទោស និងពិរុទ្ធជនយ៉ាងទៀងទាត់ ។

## **សិទ្ធិប្រើប្រាស់ដីធ្លី   និងការចិញ្ចឹមជីវិត**

- ផ្សព្វផ្សាយឱ្យសាធារណៈជនដឹងជាលំអិតអំពីសម្បទានទាំងអស់ដែលបានអនុម័តរួចហើយរួមទាំងកិច្ចសន្យា ផែនទី និងព័ត៌មានស្តីពីក្រុមហ៊ុនសម្បទាន និងម្ចាស់ភាគហ៊ុនទាំងអស់ ។

- ពង្រឹងសេចក្តីតម្រូវឱ្យពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃលើហេតុប៉ះពាល់សង្គម បរិស្ថាន ប្រកបដោយអត្ថន័យ មុននឹងផ្តល់សម្បទានដីសេដ្ឋកិច្ច ។ សម្បទានទាំងឡាយណាដែលបានផ្តល់ដោយមិនបានបំពេញតាមសេចក្តីតម្រូវនេះ គួរតែចាត់ទុកជាមោឃៈ ។

- លុបចោលសម្បទានទាំងឡាយណាដែលមិនគោរពតាមសេចក្តីតម្រូវក្នុងច្បាប់ភូមិបាល និងអនុក្រឹត្យនៃច្បាប់នេះ ។ ផ្តល់យន្តការមួយសំរាប់សហគមន៏ដែលប៉ះពាល់ អាចស្នើសុំឱ្យពិនិត្យឡើងវិញ និងលុបចោលសម្បទានដែលមិនគោរពតាមសេចក្តីតម្រូវនេះ ។

- ហាមផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត នៅក្នុងតំបន់ដែលមានព្រៃសំខាន់ៗ ។

- ហាមលក់ដី និងផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត នៅក្នុងតំបន់ដែលកាន់កាប់ដោយសហគមន៏ជនជាតិដើមភាគតិច រង់ចាំការចុះបញ្ជីដីប្រពៃណីដែលជនជាតិដើមភាគតិចកំពុងប្តឹងទាមទារ និងកិច្ចដំណើរការធ្វើប័ណ្ណកម្មសិទ្ធដីសមូហភាព ។

- បង្កើតយន្តការការពារដីជនជាតិដើមភាគតិច រង់ចាំការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព និងការបញ្ចប់កិច្ចដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិច ។

- ការពារសិទ្ធិរបស់អង្គការក្រៅរដ្ឋាភិបាល និងសកម្មជនសហគមន៍ ដែលធ្វើការតស៊ូមតិទាមទារសិទ្ធិស្មើភាពគ្នាក្នុងការប្រើដីធ្លី និងធនធានធម្មជាតិ កុំឱ្យមានការគំរាមកំហែង ការបំភិតបំភ័យឬការរិតត្បិតសកម្មភាពរបស់ពួកគេ ។ មិនត្រូវប្រើប្រព័ន្ធច្បាប់ ដើម្បីបិទមាត់ ឬដាក់ទណ្ឌកម្មសកម្មជនទាំងនោះឡើយ ។

***ការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍អន្តរជាតិ***

- ផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។

- ចូលជាសមាជិកនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ។ ធ្វើសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយឱ្យស្របជាមួយនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។

- ដាក់ជូនជាបញ្ហាអាទិភាព នៃរបាយការណ៍ដំបូងរបស់កម្ពុជាស្តីពីការអនុវត្តន៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

- លើកកំពស់ និងគោរពយ៉ាងពេញទំហឹង នូវអនុសញ្ញាឆ្នាំ១៩៥១ ស្តីពីឋានៈនៃជនភៀសខ្លួន និងពិធីសារឆ្នាំ១៩៦៧ នៃអនុសញ្ញានេះ ។

------------